# កម្រងសំណួរចម្លើយវិន័យ



*រៀបរៀងដោយ*

**ភិក្ខុនន្ទធម្មោ មហាយឿន-សុខនឿន**

**រក្សាសិទ្ធិ**

**ព.ស.២៥៥៧ គ.ស.២០២៣**

# អារម្ភកថា

កាលដែលខ្ញុំបានរៀបរៀងសៀវភៅវិន័យ ដែលមានឈ្មោះថា **កម្រងសំនួរចម្លើយវិន័យ**នេះ ដោយមានការយល់ឃើញថា វិន័យគឺជាច្បាប់សម្រាប់អប់រំពួកអ្នកបួសក្នុងព្រះពុទ្ធសាសនាឲ្យមានសុជីវធម៌ល្អ នឹងជាគំរូសម្រាប់បច្ឆាជនជាន់ក្រោយផងដែរ ។ មួយទៀតគឺធ្វើឲ្យយើងយល់ដឹងអំពីកិច្ច ដែលយើងត្រូវធ្វើ និងមិនត្រូវធ្វើ ហើយគួរប្រតិបត្តិយ៉ាងដូចម្តេច ឲ្យសាកសមជាអ្នកកាន់ព្រះពុទ្ធសាសនា ដែលយើងប្រសិទ្ធនាមថា **សាសនាសន្តិភាព** ដែលនាំមកនូវសេចក្តីសុខ នឹងភាពរីកចម្រើនរុងរឿងគ្រប់ពេលវេលា នៅលើពិភពលោក ។

ម្យ៉ាងទៀត សម្រាប់បញ្ញាជន ដែលស្រេកឃ្លាននូវចំណេះវិជ្ជាសព្វសារពើទាំងអស់ ដែលស្ថិតនៅក្នុងសម័យកាលត្រូវស្រាវជ្រាវនឹងឈ្វេងយល់ ពីសម័យកាលមួយ ទៅសម័យកាលមួយ តើវាមានភាពខុសគ្នាយ៉ាងដូចម្តេចខ្លះ ? ដូចនេះយើងត្រូវតែចេះដឹងឲ្យបានច្រើន សម្រាប់បង្កើនបញ្ញារបស់យើង ។

អាស្រ័យហេតុនេះហើយ សូមអ្នកអានទាំងឡាយ ជួយកែនូវកំហុស ខុសឆ្គងផងដែរ ដែលកើតឡើងដោយអចេតនាផ្សេងៗហើយក៏សូមជូនពរ អ្នកសប្បុរសទាំងអស់ ជួបតែសេចក្តីសុខចម្រើន គ្រប់

ពេលវេលាកុំបីខាន ។ សូមអនុមោទនា !!!

ថ្ងៃ១៣កើត ខែអស្សុជ ឆ្នាំម្សាញ់ បញ្ចស័ក ព.ស.២៥៥៧ ។
ខេត្តកណ្តាល,ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៣ ។

ភិក្ខុយឿន-សុខនឿន បរិញ្ញាបត្រជាន់ខ្ពស់
ផ្នែកវិទ្យាសាស្រ្តនយោបាយ នៃសាកលវិទ្យាល័យខេរៈ
និងជាអតីតនិស្សិតនៃសាកលវិទ្យាល័យព្រះសីហនុរាជ
ផ្នែកភាសាបាលី-សំស្រ្កឹត និងភាសាបរទេស

# ព្រះពុទ្ធសាសនាមានអង្គ ៩ គឺៈ

ព្រះពុទ្ធសាសនាគឺ ព្រះធម៌វិន័យដែលព្រះដ៏មានព្រះភាគទ្រង់សំដែងប្រកបដោយអង្គ ៩ គឺៈ

១. **សុត្ត** គឺបានដល់ព្រះសូត្រផ្សេងៗ មានមង្គលសូត្រ ជាដើម ។

២. **គេយ្យ** គឺព្រះសូត្រទាំងអស់ដែលមានគាថា មានសគាថវគ្គជាដើម ។

៣. **វេយ្យាករណ** គឺព្រះអភិធម្មបិដកព្រះសូត្រដែល មិនមានគាថាបញ្ចូលជាមួយ និងព្រះពុទ្ធវចនៈដែលមិនចាត់ចូលក្នុងអង្គ៨ ។

៤. **គាថា** គឺព្រះធម្មបទថេរគាថា ថេរីគាថា និងគាថាសុទ្ធៗដែលមិនមានឈ្មោះថា សូត្រក្នុងសុត្តនិបាត ។

៥. **ឧទាន** គឺព្រះសូត្រ ៨២ សូត្រដែលព្រះដ៏មានព្រះភាគទ្រង់ថ្លែងដោយសោមនស្សញាណ ។

៦. **ឥតិវុត្តក** គឺព្រះសូត្រ ១១០ សូត្រដែលផ្ដើមឡើង ដោយពាក្យថា វុត្តំ ហេតំ ភគវា (ខនេះសមពិតដូចពាក្យ ដែលព្រះដ៏មានព្រះភាគទ្រង់ត្រាស់ទុកមកហើយ) ។

៧. **ជាតក** គឺរឿងអតីតជាតិរបស់ព្រះដ៏មានព្រះភាគ និងព្រះអគ្គសាវ័កមានអបណ្ណជាតក ជាដើមរួម ៥៥០ ជាតក ។

៨. **អព្ភូតធម៌** គឺព្រះសូត្រដែលប្រកបដោយអច្ឆរិយ អព្ភូតធម៌ (ធម៌ដែលក្រៃលែងដោយគុណវិសេស ដែលគួរ អស្ចារ្យ) ។

៩. **វេទល្ល** គឺព្រះសូត្រ ដែលកាលណាសួរហើយ ក៏បាននូវសេចក្ដីជ្រាបនិងសេចក្ដីត្រេកអរក្រៃលែងឡើងៗ មានចូឡវេទល្លសូត្រជាដើម ។

# ប្រយោជន៍វិន័យ១០យ៉ាង

ព្រះបរមគ្រូ ទ្រង់បានបញ្ញត្តិវិន័យ ព្រោះទ្រង់យល់ប្រយោជន៍១០យ៉ាងគឺ:

១.**សង្ឃសុដ្ឋុតាយ** ដើម្បីសេចក្តីល្អដល់សង្ឃ ។

២.**សង្ឃផាសុតាយ** ដើម្បីការស្រួលដល់សង្ឃ ។

៣.**ទុម្មង្គូនំ ភិក្ខូ និគ្គហាយ** ដើម្បីញាំញីពួកភិក្ខុ ដែលទ្រុស្តសីល ។

៤.**បេសលានំ ភិក្ខូនំ ផាសុវិហារាយ** ដើម្បីនៅជាសុខដល់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ។

៥.**ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ** ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយ ក្នុងបច្ចុប្បន្ន ។

៦.**សម្បរាយិកានំ អាសវានំ បដិឃាតាយ** ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងលោក ។

៧.**អប្បសន្នានំ បសាទាយ** ដើម្បីញុំាងពួកជន ដែលមិនទាន់ជ្រះថ្លា ឲ្យជ្រះថ្លា ។

៨.**បសន្នានំ ភិយ្យោភាវាយ** ដើម្បីញុំាងពួកជនដែលជ្រះថ្លាហើយ ឲ្យរិតតែជ្រះថ្លាឡើង ។

៩.**សទ្ធម្មដ្ឋិតិយា** ដើម្បីញុំាងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ ។

១០.**វិនយានុគ្គហាយ** ដើម្បីអនុគ្រោះ ដល់ព្រះវិន័យ៤យ៉ាង មានសំវរៈវិន័យជាដើម ។

## អានិសង្សអ្នកទ្រទ្រង់វិន័យ៥យ៉ាង

១.**អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ** វិន័យធរភិក្ខុ មានសីលក្ខន្ធរបស់ខ្លួន គ្រប់គ្រងល្អហើយរក្សាត្រឹមត្រូវល្អហើយគឺថា មិនបានត្រូវនូវអាបត្តិតូច-ធំ ។

២.**កុក្កុច្ចប្បកតានំ បដិស្សរណំ ហោតិ** វិន័យធរភិក្ខុ នឹងបានជាទីពុំនាក់កុលបុត្រទាំងឡាយដែលមានសេចក្តីសង្ស័យ ។

៣.**វិសារទោ សង្ឃមជ្ឈេ វោហរតិ** វិន័យធរភិក្ខុ នឹងក្លៀវក្លានិយាយវិន័យក្នុងកណ្តាលនៃជុំនុំសង្ឃ ។

៤.**បច្ចត្ថិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ** វិន័យធរភិក្ខុ អាចនិងសង្កត់សង្កិនបុគ្គល ដែលជាសត្រូវក្នុងសាសនាដោយសហធម៌ គឺពាក្យប្រកបដោយហេតុបាន ។

៥.**សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ** វិន័យធរភិក្ខុ បានប្រតិបត្តិត្រឹមត្រូវល្អហើយ ដើម្បីញុំាងព្រះសទ្ធម្មឲ្យដំកល់នូវមាំបាន ។

# សង្ខេបព្រះត្រៃបិដក

ព្រះវិន័យបិដកមាន២វិភង្គគឺ ភិក្ខុវិភង្គ និងភិក្ខុនីវិភង្គ ។ វិភង្គទាំងពីរនេះហៅថា ឧភតោវិភង្គ ។

**១.ភិក្ខុវិភង្គ មាន៨ កណ្ឌ និងមាន ២២៧ សិក្ខាបទ ។**

ក.**បារាជិកកណ្ឌ** មាន ៤ សិក្ខាបទ ។

ខ.**តេរសកណ្ឌ** មាន ១៣ សិក្ខាបទ ។

គ.**អនិយតកណ្ឌ** មាន ២ សិក្ខាបទ ។

ឃ.**និស្សគ្គិយកណ្ឌ** មាន ៣០ សិក្ខាបទ ។

ង.**សុទ្ធិកបាចិត្តិយកណ្ឌ** មាន ៩២ សិក្ខាបទ ។

ច.**សេក្ខិយកណ្ឌ** មាន ៧៥ សិក្ខាបទ ។

ឆ.**អធិករណសមថកណ្ឌ** មាន ៧ សិក្ខាបទ ។

ជ.**បាដិទេសនិយ** មាន ៤ សិក្ខាបទ ។

**២.ភិក្ខុនីវិភង្គ មាន ៧ កណ្ឌ និងមាន ៣១០ សិក្ខាបទ ។**

ក.**បារាជិកកណ្ឌ** មាន ៨ សិក្ខាបទ ។

ខ.**សត្តរសកណ្ឌ** មាន ១៧ សិក្ខាបទ ។

គ.**និស្សគ្គិយកណ្ឌ** មាន ៣០ សិក្ខាបទ ។

ឃ.**សុទ្ធិកបាចិត្តិយកណ្ឌ** មាន ១៦៦ សិក្ខាបទ ។

ង.**បាដិទេសនីយកណ្ឌ** មាន ៧ សិក្ខាបទ ។

ចៈ**សេក្ខិយកណ្ឌ** មាន ៧៥ សិក្ខាបទ ។

ឆ.**អធិករណសមថកណ្ឌ** មាន ៧ សិក្ខាបទ ។

**ព្រះវិន័យបិដក មាន ៥ គម្ពីរ**

១.គម្ពីរ **អាទិកម្ម**

២.គម្ពីរ **បាចិត្តិយ**

៣.គម្ពីរ **មហាវគ្គ**

៤.គម្ពីរ **ចុល្លវគ្គ**

៥គម្ពីរ **បរិវារ** ។

ដើម្បីងាយស្រួលចាំគម្ពីរទាំង៥នេះ គេសរសេរជាអក្សរកាត់ថា «អា-,បា-,ម-,ចុ-,ប- »។ ចែកជាសៀវភៅមាន១៣ក្បាល ចែកជាធម្មក្ខន្ធ មាន ២១០០០ ធម្មក្ខន្ធ ។ ចាប់ពីលេខ ០១ ដល់លេខ ១៣ ។

**ព្រះវិន័យទាំងអស់មានអត្ថ៣ប្រការគឺៈ**

១.**វិវិធនយត្តា** ព្រោះអត្ថថា មានន័យផ្សេងៗ ។

២.**វិសេសនយត្តា** ព្រោះអត្ថថា មានន័យដ៏វិសេស ។

៣.**កាយវាចានំ វិនយត្តោ** ព្រោះអត្ថថា ជាគ្រឿងកាត់ឬទូន្មាននូវកាយនឹងវាចា ។

**ព្រះសុត្តន្តបិដក មាន ៥ គម្ពីរ**

១.គម្ពីរ **ទីឃនិកាយ**

២.គម្ពីរ **មជ្ឈិមនិកាយ**

៣.គម្ពីរ **សំយុត្តនិកាយ**

៤.គម្ពីរ **អង្គុត្តរនិកាយ**

៥.គម្ពីរ **ខុទ្ទកនិកាយ** ។

ដើម្បីងាយចាំ គម្ពីរទាំង៥នេះ ត្រូវបានគេសរសេរជាអក្សរកាត់ថា «ទី-,ម-,សំ-,អំ-,ខុ- » ។ ចែកជាសៀវភៅ មាន ៦៤ ក្បាល ចែកជាធម្មក្ខន្ធ មាន ២១០០០ ធម្មក្ខន្ធ ។ ចាប់ពីលេខ ១៤ ដល់លេខ ៧៧។

**ព្រះសូត្រទាំងអស់មានអត្ថ៦ប្រការគឺ:**

១.**សូចនតោ** ព្រោះសម្តែងចេញនូវប្រយោជន៍ដល់សត្វដទៃ។

២.**សុវុត្តតោ** ព្រោះសម្តែងអនុលោមតាមអធ្យាស្រ័យនឹងចរិតរបស់វេនេយ្យសត្វ ។

៣.**សវនតោ** ព្រោះឲ្យសម្រេចប្រយោជន៍ដល់សព្វសត្វ ដូចស្រូវសន្ទូងឲ្យសម្រេចផល ។

៤.**សូទនតោ** ព្រោះជាទីហូរចេញនៃផល ដូចដោះមេគោដែលជាទីហូរចេញនៃទឹកដោះ ។

៥.**សុត្តណា** ព្រោះរក្សាទុកនៅប្រយោជន៍ដោយល្អដល់សត្វអ្នកប្រតិបត្តិ ។

៦.**សុត្តសភាគតោ** ព្រោះជាមាគ៌ាដ៏ត្រង់បើកឲ្យសត្វ អ្នកប្រតិបត្តិដើរឆ្ពោះទៅស្ថានព្រះនិព្វាន ដូចខ្សែបន្ទាត់នៃជាងឈើ ។

**ព្រះអភិធម្មបិដក មាន ៧ គម្ពីរ**

១.គម្ពីរ **សង្គណី**

២.គម្ពីរ **វិភង្គ**

៣.គម្ពីរ **ធាតុកថា**

៤.គម្ពីរ **បុគ្គលប្បញ្ញត្តិ**

៥.គម្ពីរ **កថាវត្ថុ**

៦.គម្ពីរ **យមក**

៧.គម្ពីរ **បដ្ឋាន** ។

គម្ពីរទាំង៧នេះ គេសរសេរជាអក្សរកាត់ឲ្យងាយចាំថា «សំ,វិ,ធា,បុ,ក,យ,ប »។ ចែកជាសៀវភៅមាន ៣៣ ក្បាល ចែកជាធម្មក្ខន្ធមាន ៤២០០០ ធម្មក្ខន្ធ ។ ចាប់ពីលេខ ៧៨ ដល់ លេខ ១១០។

**ព្រះអភិធម្មមានអត្ថ៥ប្រការគឺៈ**

១.**វុឌ្ឍិមន្តោ** មានអត្ថថា ធម៌មានសេចក្តីចម្រើន ។

២.**សលក្ខណា** មានអត្ថថាធម៌ប្រកបដោយសេចក្តីកំណត់ ។

៣.**បូជិតា** មានអត្ថថា ធម៌គួរបូជា ។

៤.**បរិច្ឆិន្នា** មានអត្ថថា ធម៌ជាចំណែកៗមិនច្រឡំគ្នា ។

៥.**អធិកា** មានអត្ថថា ធម៌ដ៏ក្រៃលែង ។

**គម្ពីរព្រះធម្មសង្គណីចែកជា ៤ កណ្ឌគឺ:**

១.**ចិត្តវិភត្តិកណ្ឌ** ចែកចិត្តចេតសិកជាដើម ។

២.**រូបវិភត្តិកណ្ឌ** ចែករូបជាដើម ។

៣.**និក្ខេបរាសកណ្ឌ** ចែកធម៌ក្នុងបទមាតិកានោះ ។

៤.**អត្ថុទ្ធារកណ្ឌ** ចែកអត្ថជាដើម ។

**គម្ពីរវិភង្គ** ចែកវិភង្គ១៨ប្រការមានខន្ធវិភង្គជាដើម

**គម្ពីរធាតុកថា** ពោលការសង្គ្រោះធម៌ ដែលចាត់ជាកងធាតុផ្សេងៗ ជាដើម ។

**គម្ពីរបុគ្គលប្បញ្ញត្តិ** ពោលអំពីបញ្ញត្តិ ៦ ប្រការមានខន្ធប្បញ្ញត្តិជាដើម ។

**គម្ពីរកថាវត្ថុ** ចែកព្រះសូត្រជាចំណែកនៃសកវាទីនឹងបរវាទីជាដើម ។

**គម្ពីរយមក** ចែកធម៌ចេញជាគូៗ ដូចធម៌ជាចំណែកកុសលនឹងមូលនៃធម៌ជាចំណែកកុសលជាដើម ។

**គម្ពីរមហាបដ្ឋាន** ចែកធម៌ប្រកបដោយហេតុនឹងបច្ច័យជាដើម ។

***សរុបធម្មវិន័យក្នុងព្រះត្រៃបិដកមាន ៨៤០០០ ព្រះធម្មក្ខន្ធ គិតជាសៀវភៅ មាន ១១០ ក្បាល ។***

*ពាក្យថា វិន័យនេះ មានគោល ៣ ផ្នែកគឺ: បញ្ញត្តិ១,អនុញ្ញាត១,អភិសមាចារ១ ។ ខដែលព្រះសព្វញ្ញុពុទ្ធទ្រង់ហាមមិនឲ្យបព្វជិតប្រព្រឹត្តពាយផាយតាមអំពើចិត្ត ព្រមទាំងប្រាប់ទោសកំហុសធ្ងន់ស្រាលផង ហៅថាបញ្ញត្តិ ឬពុទ្ធានុញ្ញាត ។ ខ ដែលទ្រង់យល់ព្រមឲ្យធ្វើឲ្យប្រព្រឹត្តបាន ហៅថា អនុញ្ញាត ឬពុទ្ធានុញ្ញាត ។ ការប្រព្រឹត្តរៀបរយល្អ ឬកិច្ចវត្តដែលបព្វជិតត្រូវប្រព្រឹត្ត ត្រូវបំពេញឲ្យបរិបូណ៌ ហៅថា អភិសមាចារ ។ រួមទាំង៣ ផ្នែកនេះ ហៅថា វិន័យ ។*

***១/សំនួរ ពាក្យថាវិន័យ បានដល់អ្វី ? មានប៉ុន្មានយ៉ាង ? វិន័យពួកណាសម្រាប់ជនណា ? ព្រះពុទ្ធសាសនា បើគ្មានវិន័យទេនឹងទៅជាយ៉ាងណា ?***

***ចម្លើយ*** *ពាក្យថាវិន័យ បានដល់ច្បាប់ជាពុទ្ធានុញ្ញាតនិងពុទ្ធប្បញ្ញត្តិទាំងអស់ ដែលព្រះពុទ្ធទ្រង់អនុញ្ញាត និងហាមប្រាមដល់សាវ័កព្រះអង្គ ។ វិន័យ មានច្រើនណាស់ តែបើនិយាយដោយខ្លីមានតែ២យ៉ាងគឺ:*

*ក.អគារិយវិន័យ វិន័យសម្រាប់អ្នកនៅគ្រប់គ្រងផ្ទះ គឺគ្រហស្ថយរាវាស ជាឧបាសក និងឧបាសិកា ។*

ខ.អនាគារិយវិន័យ វិន័យសម្រាប់អ្នកមិននៅគ្រប់គ្រងផ្ទះ គឺពួកអ្នកបួស មានភិក្ខុ និងសាមណេរនេះឯង ។

ព្រះពុទ្ធសាសនា បើគ្មានវិន័យទេ និងត្រូវសាបសូន្យ អត្តរាយអត្តរធានទៅបាន ។

**២/សំនួរ ពាក្យថា ត្រៃសិក្ខា ធម៌វិន័យ និងសាសនាទាំង៣ នេះមានសេចក្តីផ្សេងៗគ្នាយ៉ាងណា ? ឬក៏ដូចគ្នា ?**

**ចម្លើយ** ផ្សេងគ្នាដោយព្យញ្ជន តែជាសការៈដូចគ្នាដោយអត្តគឺ សីលសិក្ខា នឹងបញ្ញាសិក្ខាជាផ្នែកខាងកាយ និងវាចាបានខាងព្រះវិន័យចិត្តសិក្ខា និងបញ្ញាសិក្ខា ដែលជាប្រតិបត្តិខាងផ្លូវចិត្តសិក្ខារួមចូលក្នុងផ្លូវធម៌ផង ធម៌និងវិន័យនេះជាឱវាទរបស់ព្រះពុទ្ធជាម្ចាស់ដូចគ្នា រួមទាំងអស់ហៅថា(សាសនា) ដែលប្រែថា ពាក្យប្រៀនប្រដៅនេះឯង ។

**៣/សំនួរ ពាក្យថា សិក្ខា និងសិក្ខាបទ ទាំងពីរម៉ាត់នេះមានសេចក្តី អធិប្បាយដូចម្តេច ?**

**ចម្លើយ** សិក្ខា ប្រែថា ការសិក្សា ការរៀនសូត្រស្វាធ្យាយន៍ការធ្វើកាយវាចាឲ្យថ្នឹក ឲ្យស្អាត់មិនឲ្យឆ្គាំឆ្គង គឺជាធម្មជាតិដែលបុគ្គលត្រូវរៀនសូត្រ ។

រីឯពាក្យថា សិក្ខាបទវិញ បានដល់វិនយប្បញ្ញត្តិ ដែលព្រះ

សម្មាសម្ពុទ្ធទ្រង់ហាម លើកឡើងជាប្រការ ឬជាមាត្រាមួយៗ ហៅថា សិក្ខាបទៗ នោះមាននៅក្នុងបាដិមោក្ខខ្លះ មិនមាននៅក្នុងបាដិមោក្ខខ្លះ ។ ឯសិក្ខាបទដែលមានក្នុងបាតិមោក្ខនោះគឺ បារាជិក៤,សង្ឃាទិសេស១៣,អនិយត២,និស្សគ្គិយបាចិត្តិយ៣០,សុទ្ធិកបាចិត្តិយ៩២, បាដិទេសនិយ៤,សេក្ខិយវត្ត៧៥ រួមជា ២២០ រាប់អធិករណសមថ ៧ ផង ត្រូវជា ២២៧ ។

**៤/សំនួរ ចតុប្បារិសុទ្ធិសីលមានប៉ុន្មាន ? គឺអ្វីខ្លះ ?**

**ចម្លើយ** ចតុប្បារិសុទ្ធិសីលមាន ៤ យ៉ាងគឺ បាតិមោក្ខសំវរៈសីល១,ឥន្ទ្រីយសំវរៈសីល១,អាជីវបារិសុទ្ធិសីល១ និងបច្ចយសន្និស្សិតសីល១ ។

**៥/សំនួរ ចុះនៅក្នុងឥន្ទ្រីយសំវរៈសីល ដូចម្តេចហៅថា ឥន្ទ្រីយ ? ឥន្ទ្រីយនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ? ការសង្រួមក្នុងឥន្ទ្រីយទាំងនោះត្រូវធ្វើដូចម្តេច ? ចូរអធិប្បាយ ?**

**ចម្លើយ** ឥន្ទ្រីយ ប្រែថា ធម្មជាតិជាធំ ដូចមានវិគ្គហថា ឥន្ទតិ បរិមិស្ស រិយំ ករោតីតិ = ឥន្ទ្រីយំ (ធម្មជាតិ) ធម្មជាតិណាជាធំ គឺធ្វើនូវភាពនៃខ្លួនជាយ៉ាងក្រៃលែង ធម្មជាតិនោះឈ្មោះឥន្ទ្រីយ ឥន្ទ្រីយនោះមាន ៦ យ៉ាងគឺ:

**១.ចក្ខុន្ទ្រិយ** ឥន្ទ្រីយគឺ ភ្នែក

២.**សោតិន្ទ្រិយ** ឥន្ទ្រីយគឺ ត្រចៀក

៣.**ឃានិន្ទ្រិយ** ឥន្ទ្រីយគឺ ច្រមុះ

៤.**ជីវ្ហិន្ទ្រិយ** ឥន្ទ្រីយគឺ អណ្តាត

៥.**កាយិន្ទ្រិយ** ឥន្ទ្រីយគឺ កាយ

៦.**មនិន្ទ្រិយ** ឥន្ទ្រីយគឺ ចិត្ត

អធិប្បាយថា ពាក្យថា សំវរៈ ប្រែថា ការសង្រួមបិទបាំង,រវាំងប្រយ័ត្ន មិនឲ្យអារម្មណ៍ទាំងឡាយគឺ រូប សម្លេង ក្លិន រស និងសម្ផស្ស ធម៌ណាមួយដែលទោសកើតឡើងបាន រួមសេចក្តីមកហៅថា ឥន្ទ្រីយសំវរៈសីល គឺការសង្រួមនូវ ឥន្ទ្រីយ ។

**៦/សំនួរ បើបានសង្រួមឥន្ទ្រីយហើយ តើភិក្ខុ សាមណេរបានអានិសង្សយ៉ាងណា ? ចូរពន្យល់ ?**

**ចម្លើយ** បើភិក្ខុ សាមណេរ បានសង្រួមនូវឥន្ទ្រីយដ៏ម៉ត់ចត់ហើយរមែងបាននូវសេចក្តីសុខលើសប្រមាណ មានសុខក្នុងឈាននិងសុខក្នុងមគ្គផលជាដើម ។ ផ្ទុយទៅវិញ បើមិនបានសង្រួមទេ ត្រូវទទួលនូវការនិន្ទាតិះដៀលអំពីសំណាក់វិញ្ញូជនក្នុងបច្ចុប្បន្ននេះផង, លុះដល់ធ្វើកាលកិរិយាទៅកាន់លោកខាងមុខ និងបានទៅកាន់ទុគ្គតិ នរក ប្រេត តិរច្ឆាន ជាប្រត្យក្សបើមិនមួយក៏មួយដែរខានពុំបានឡើយ ។

**៧/សំនួរ បច្ច័យ ក្នុងបច្ច័យសន្និស្សតិសីលបានសេចក្ដីថា ដូចម្ដេច ? បច្ច័យនោះមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?**

**ចម្លើយ** ពាក្យថា បច្ច័យបានសេចក្ដីថា គ្រឿងដែលបុគ្គលត្រូវអាស្រ័យ បរិភោគ ប្រើប្រាស់ ហើយប្រព្រឹត្តទៅបាន ។ សត្វទាំងឡាយក្នុងពិភពលោកយើងនេះសុទ្ធតែពឹងពាក់អាស្រ័យ នៅលើបច្ច័យនេះទាំងអស់ ។ ដោយហោចណាស់ក៏ត្រូវការបច្ច័យណាមួយដែរ ក្នុងបច្ច័យទាំង៤នេះ ទើបញ៉ាំងចរន្តអាចរស់នៅបានដែរ ។

បច្ច័យ ៤ នោះគឺ:

១.ចីវរប្បច្ច័យ

២.បិណ្ឌបាតប្បច្ច័យ

៣.សេនាសនប្បច្ច័យ

៤.គិលានភេសជ្ជប្បច្ច័យ ។

**៨/សំនួរ ការពិចារណានូវបច្ច័យទាំងនោះ ហៅថាអ្វី ? មានន័យដូចម្ដេច ? ក្នុងបច្ច័យនិមួយៗមានបច្ចវេក្ខណៈប៉ុន្មាន ? គឺអ្វីខ្លះ ? ក្នុងបច្ចវេក្ខណៈនិមួយៗ ? មានសេចក្ដីដូចម្ដេចខ្លះ ? ចូរអធិប្បាយ ?**

**ចម្លើយ** ការពិចារណានូវបច្ច័យទាំងនោះ ហៅថា បច្ចវេក្ខណមានន័យថា ការរំពឹង,ការរិះគិត,ការត្រិះរិះ,សង្កេត,ពិនិត្យ ឈ្វេចឈ្វីលំអិតសេចក្ដីឲ្យយល់ជាក់ពុំមែនគ្រាន់តែសូត្រឲ្យគ្រាន់តែពុ្ធ ហើយពុំ

យល់សេចក្តីថាម៉េចនោះទេ ។

ក្នុងបច្ច័យនិមួយៗមានបច្ច័យវេក្ខណៈ៤គឺៈ

១.ធាតុប្បច្ចវេក្ខណៈ

២.បដិកូលប្បច្ចវេក្ខណៈ

៣.តំខណិប្បច្ចវេក្ខណៈ

៤.អតីតប្បច្ចវេក្ខណៈ

ក្នុងបច្ចវេក្ខណនិមួយៗ មានសេចក្តីអធិប្បាយតទៅៈ

កាលបើបព្វជិតបានទទួលនូវបច្ច័យណាមួយទោះចីវរប្ប-ច្ច័យក្តី បិណ្ឌបាតប្បច្ច័យក្តី សេនាសនប្បច្ច័យក្តី គិលានភេសជ្ជប្បច្ច័-យក្តី ត្រូវតែពិចារណាក្នុងពេលដំណាលគ្នា និងការទទួលនូវបច្ច័យនោះឯង ។

ម្យ៉ាងទៀតអាភោគចិត្ត គឺរំពឹងពិចារណាក្នុងចិត្តមានលក្ខណតាមលក្ខណៈនៃបច្ចយវេក្ខណៈវិធីនោះ ។

**៩/សំនួរ បច្ចវេក្ខណកាល គឺកាលដែលត្រូវពិចារណាមានប៉ុន្មាន ? គឺអ្វីខ្លះ ? រួមកាលទាំងអស់ដែលត្រូវពិចារណាមានប៉ុន្មាន ? ចូរអធិប្បាយឲ្យសព្វគ្រប់មកមើល ?**

**ចម្លើយ** បច្ចវេក្ខណកាល គឺកាលដែលត្រូវពិចារណាមាន៣យ៉ាង ។

១.**បដិលាភកាល** គឺកាលកំពុងបាន ឬកាលកំពុងទទួលនូវបច្ច័យ ។

២.**បរិភោគកាល** គឺកាលដែលកំពុងបរិភោគប្រើប្រាស់ ។

៣.**អតីតកាល** គឺកាលដែលបានបរិភោគប្រើប្រាស់រួចហើយ រួមកាលទាំងអស់មាន១២ ។

បណ្ដាកាលទាំងបី ដូចបានពោលរួចមកហើយនេះ ក្នុងបដិលាភកាល គឺកាលកំពុងបាន កំពុងទទួលនូវបច្ច័យត្រូវពិចារណាដោយធាតុប្បច្ចវេក្ខណៈ ក៏បានដោយបដិកូលប្បច្ចវេក្ខណៈ ។

**១០/សំនួរ ថ្ងៃចូលព្រះវស្សាមានប៉ុន្មានប្រភេទ ? គឺអ្វីខ្លះ ?**

**ចម្លើយ** ថ្ងៃចូលព្រះវស្សាមាន ២ ប្រភេទគឺៈ

១.**បុរិមិគា វស្សូបនាយិការ** ការចាំវស្សាមុនគឺកំណត់ចូលពីថ្ងៃ ១រោជ ខែអាសាធ ទៅដល់ថ្ងៃទី១៥ កើតពេញបូណ៌មីខែអស្សុជ ។

២.**បច្ឆិមិការ វស្សូបនាយិការ** ការចាំវស្សាលើកក្រោយគឺកំណត់ចូលពីថ្ងៃ ១រោជ ខែស្រាពណ៌ ទៅចេញនៅថ្ងៃ ១៥កើត ខែកត្តិក ។

**១១/សំនួរ បើកាលណាភិក្ខុ សាមណេរបានចូលវស្សាត្រឹមត្រូវដោយគ្មានដាច់ខ្វះខាតអ្វីទេ តើត្រូវបានអានិសង្សដែរឬទេ ? បើបានតើអានិសង្សនោះមានប៉ុន្មាន ? គឺអ្វីខ្លះ ? ចូរពន្យល់ឲ្យក្បោះ**

ក្បាយមកមើល?

**ចម្លើយ** ចំពោះភិក្ខុដែលបានគង់ចាំវស្សាអស់ត្រៃមាសហើយ ព្រះពុទ្ធទ្រង់ប្រទានកម្រៃ៥យ៉ាង រឺឯកម្រៃអានិសង្ស៥យ៉ាងគឺ:

១.ទៅណាមកណាមិនចាំបាច់លាភិក្ខុផងគ្នាតាមសិក្ខាបទទី ៦ នៃអចេលកវគ្គបាចិត្តិយកណ្ឌ ។

២.ទៅណាមកណាមិនចាំបាច់យកត្រៃចីវរគ្រប់ប្រដាប់ ។

៣.ទុកដាក់អតិរេកចីវរបានតាមប្រាថ្នា ។

៤.ឆាន់គណៈភោជន និងបរម្បរៈភោជនបាន ។

៥.មានសិទ្ធិត្រូវបានចីវរដែលកើតឡើងក្នុងដែននៅចាំវស្សានោះ ។

សូមបញ្ជាក់ថា អានិសង្សទាំង៥ យ៉ាងនេះត្រូវកំណត់បាន ១ ខែ ចាប់តាំងពីថ្ងៃពេញបូណ៌មី ខែកត្តិកដើម ដល់ថ្ងៃខែដាច់ កត្តិកនេះ ថែមទាំងបានដើម្បីក្រាលកឋិន ដែលជួយលាតត្រដាងអានិសង្ស ៥ នេះឲ្យបានអាយុវែង ដល់ថ្ងៃពេញបូណ៌មីខែ ផល្គុន គឺពេញមួយហេមន្តរដូវទៀត ។

**១២/សំនួរ កន្លែងដូចម្តេចដែលព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យចាំវស្សាបាន? កន្លែងដូចម្តេចដែលទ្រង់ហាម?**

**ចម្លើយ** ទីដែលមានសេនាសនៈប្រក់បិទបាំង និងមានទ្វារ

ចេញចូលបាន ទីបែបនេះទើបព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យចាំវស្សាបាន។ ហាមមិនឲ្យនៅចាំវស្សាក្នុងខ្ទមខ្មោច ក្នុងពាង ក្នុងឆត្រ ក្នុងរន្ធប្រហោងឈើ និងប្រគាបឈើ ។

**១៣/សំនួរ ភិក្ខុត្រូវអាបត្តិបារាជិក ឈ្មោះថា ដាច់សិទ្ធិជាភិក្ខុភាព ។ តែគេចង់ដឹងថាដល់ថ្ងៃក្រោយបើអ្នកនោះចូលមកសុំខមាទោស និងសង្ឃ តើសង្ឃអាចអត់ទោសឲ្យហើយអនុញ្ញាតឲ្យបព្វជ្ជាឬឧបសម្បទាបានដែរឬទេ ? (ប្រឡងចេញឆ្នាំ ១៩៦៥ ) ។**

**ចម្លើយ** សង្ឃអាចអនុញ្ញាតឲ្យបព្វជ្ជាបាន តែឧបសម្បទាមិនបានទេ ។

**១៤/សំនួរ ភិក្ខុមានអាធ្យាស្រ័យ ជាប្រយោជន៍បានសម្ដែងធម៌ទូន្មានមាតុគ្រាមតែពីរនាក់ដែលមិនមានបុរសដឹងក្ដីនៅជាមួយផង ចំនួន ២០ ម៉ាត់ តើភិក្ខុនោះត្រូវអាបត្តិដែរឬទេ ? បើត្រូវ តើត្រូវដោយអាបត្តិអ្វី ? ឈ្មោះសមុដ្ឋានអ្វី ?**

**ចម្លើយ** ភិក្ខុនោះឈ្មោះថា ត្រូវអាបត្តិយ៉ាងពិតប្រាកដគឺ អាបត្តិបាចិត្តិយ ដោយសមុដ្ឋានទី២ ឈ្មោះធម្មទេសនាសមុដ្ឋាន ។

**១៥/សំនួរ ក្នុងព្រះវិន័យមានចែកការកសង្ឃសម្រាប់ធ្វើសង្ឃកម្មជាប៉ុន្មានពួក ? អ្វីខ្លះ ? ហើយពួកណាមានសមត្ថកិច្ចក្នុងសង្ឃកម្មណា ?**

**ចម្លើយ** មានបែកការកសង្ឃសម្រាប់ធ្វើសង្ឃកម្មជា៥ពួក ក្នុងព្រះវិន័យ គឺ:

១.**សង្ឃចតុវគ្គ** មានភិក្ខុ៤រូប

២.**សង្ឃបញ្ចវគ្គ** មានភិក្ខុ៥រូប

៣.**សង្ឃទសវគ្គ** មានភិក្ខុ១០រូប

៤.**សង្ឃវិសតិវគ្គ** មានភិក្ខុ២០រូប

៥.**សង្ឃអតិរេកវិសតិវគ្គ** មានភិក្ខុលើសពី២០រូប ។

សង្ឃចតុវគ្គមានសមត្ថកិច្ចក្នុងសង្ឃកម្មទាំងអស់លើកលែងតែបវារណាកម្ម កឋិនកម្ម ឧបសម្បទាកម្ម និងអព្ភានកម្មចេញ ។

សង្ឃបញ្ចវគ្គ មានសមត្ថកិច្ចក្នុងសង្ឃកម្មគ្រប់ទាំងអស់លើកលែងតែឧបសម្បទាកម្មក្នុងមជ្ឈមប្រទេស និងអព្ភានកម្មចេញ ។

សង្ឃទសវគ្គ មានសមត្ថភាពធ្វើកម្មបានទាំងអស់ លើកលែងតែអព្ភានកម្មមួយចេញ ។

សង្ឃវីសតិវគ្គទាំងពីនេះមានសមត្ថភាពអាចធ្វើសង្ឃកម្មបានទាំងអស់ឥតមានហាមឡើយ ។

**១៦/សំនួរ តើកាលិកមានប៉ុន្មានយ៉ាង ?**

**ចម្លើយ** កាលិកមាន៤យ៉ាងគឺ:

១.**យាវកាលិក** មានកំណត់កាលពីត្រឹមពេលព្រឹកទៅទល់

និងថ្ងៃត្រង់ ដូចជាបាយ ត្រីសាច់ នំចំណីជាដើម ។

២.**យាមកាលិក** មានកំណត់កាល ពីត្រឹម១ថ្ងៃ១យប់ដូចទឹកអដ្ឋបាន ៨ យ៉ាង មានទឹកបានធ្វើអំពីផ្លែស្វាយជាដើម ។

៣.**សត្តាហកាលិក** មានកំណត់កាល៧ថ្ងៃបានដល់ភេសជ្ជ ៥ យ៉ាងមានទឹកដោះរាវ ទឹកខាប់ ប្រេង ស្ករអំពៅជាដើម ។

៤.**យាវជីវិក** មានកំណត់កាលលុះត្រាតែអស់ដូចជាភេសជ្ជៈជាថ្នាំកែរោគ ។

**១៧/សំនួរ នៅក្នុងនិស្សគ្គិយបាចិត្តិយនិទ្ទេស មានការនិយាយជាប់ទាក់ទងដោយគ្រឿងចីវរជាដើម ជាហេតុឲ្យមានការឆ្ងល់ថា អកាលចីវរ អច្ចេកចីវរ អតិរេកចីវរ នោះមានសេចក្ដីផ្សេងគ្នាមកយ៉ាងណា? សូមវែកញែកឲ្យបានច្បាស់លាស់ ។**

**ចម្លើយ** ចីវរដែលភិក្ខុបានមកនៅខាងក្រៅចីវរកាលក្រៅនៃអានិសង្សកឋិន លោកហៅថា «អកាលចីវរ» ចាប់តាំងពីថ្ងៃ ៥កើតខែអស្សុជទៅ ដល់ ១០ថ្ងៃ បើមានទាយក ទាយិកា គេប្រញាប់ប្រញាល់ប្រគេនសំពត់ដោយប្រារព្ធ នូវហេតុណាមួយសំពត់យ៉ាងនេះហៅថា «អច្ចេកចីវរ» ។

សំពត់ដែលសល់លើសពីត្រៃចីវរ នៅប្រក្រតីតូចបំផុតមានបណ្ដោយ ៨ ធ្នាប់ទទឹង ៤ ធ្នាប់ហៅថា «អតិរេកចីវរ» ។

សូមបញ្ជាក់ថា អកាលចីវរ និងអតិរេកចីវរ មានន័យដូចគ្នា ខុសគ្នាតែត្រង់បានមកមិនស្របពេលគ្នាប៉ុណ្ណោះ ប៉ុន្តែជាចីវរក្រៅពីត្រៃចីវរ ជាប្រក្រតីដូចគ្នា ។

**១៨/សំនួរ តើអនាគារិយវិន័យមានប៉ុន្មានយ៉ាង ?**

**ចម្លើយ** អនាគារិយវិន័យមាន ៤ យ៉ាងគឺៈ

សំវរវិនិ័យ១ បហាវិន័យ១ សមថវិន័យ១ និងបញ្ញត្តិវិន័យ ។

**ក.សំវរន័យមាន ៥ យ៉ាងគឺៈ**

១.**សីលសំវរ** ការសង្រួមក្នុងបាតិមោក្ខ ។

២.**សតិសវរ** ការសង្រួមក្នុងឥន្ទ្រីយ៍ទាំង៦ ។

៣.**ញាណសំវរ** ការសង្រួមបិទបាំងតណ្ហាដោយបញ្ញា ។

៤.**ខន្តិសំវរ** ការសង្រួមអត់ធន់ និងក្តៅត្រជាក់ ។

៥.**វិរិយសំវរ** ការប្រឹងប្រែងមិនឲ្យ វិតក្កចូលបៀតបៀន ។

**ខ.បហានវិន័យមាន ៥ យ៉ាងគឺៈ**

១.**តទង្គប្បហាន** បានដល់ការលះកិលេសជាខណៈគឺ ត្រូវលះដោយការធ្វើទាន សីល ភាវនា ។

២.**វិក្ខម្ភនប្បហាន** បានដល់ការឈ្នះឈ្នីនូវនីវរណទាំង៥ ឲ្យស្ងប់រម្ងាប់ គឺត្រូវលះដោយ សីល សមាធិ បញ្ញា ។

៣.**សមុច្ឆេទប្បហាន** បានដល់អរិយមគ្គដែលលះកិលេសគឺ

លះដោយនិរោធប្បដិបទា ។

៤.**បដិប្បស្សទ្ធិប្បហាន** បានដល់អរិយផលដែលលះកិលេស ។

៥.**និស្សរណប្បហាន** បានដល់ព្រះនិព្វានដែលលះកិលេស។

**១៩/សំនួរ អានិសង្សរបស់កឋិនមានប៉ុន្មាន ? គឺអ្វីខ្លះ ?**

**ចម្លើយ** អានិសង្សរបស់កឋិនមាន៥ប្រការគឺៈ

១.**អនាមន្តចារោ** ត្រាច់ទៅណាមិនបាច់លាភិក្ខុផងគ្នា ឲ្យរួចចាកអាបត្តិក្នុងចារិកសិក្ខាបទទី៦ក្នុងអចេលកវគ្គ សុទ្ធិកបាចិត្តិយ ។

២.**អសមាទានចារោ** ត្រាច់ទៅណាមិនបាច់យកត្រៃចីវរគ្រប់ប្រដាប់ ឲ្យរួចចាកអាបត្តិ ក្នុងទុតិយកឋិនសិក្ខាបទទី២ ក្នុងចីវរវគ្គ និស្សគ្គិយបាចិត្តិយ ។

៣.**គណភោជនំ** ឆាន់គណភោជនបាន ឲ្យរួចចាកអាបត្តិ ក្នុងគណភោជនបាន ឲ្យរួចចាកអាបត្តិក្នុងគណភោជនសិក្ខាបទទី២ ក្នុងភោជនវគ្គ សុទ្ធិកបាចិត្តិយ ។

៤.**យាវទត្ថចីវរំ** ទុកដាក់អតិរេកចីវរបានតាមត្រូវការ ឲ្យរួចចាកអាបត្តិ ក្នុងបឋមកឋិនសិក្ខាបទទី១ ក្នុងចីវរវគ្គ និស្សគ្គិយបាចិត្តិយ ។

៥.**យោ ច តត្ថ ចីវរុប្បាទោ សោ នេសំ ភវិស្សតិ** ចីវរណាដែល

កើតឡើងក្នុងអាវាសនោះចីវរនោះត្រូវបានដល់ភិក្ខុទាំងនោះ, ភិក្ខុទាំងនោះមានសិទ្ធិទទួលចំណែកលាភដែលកើតឡើងក្នុងអាវាសនោះ ។

**២០/សំនួរ តើមាតិកានាំឲ្យកឋិនដោះមានប៉ុន្មានប្រការ ? គឺអ្វីខ្លះ ?**

**ចម្លើយ** មាតិនាំឲ្យកឋិនដោះមាន៨ប្រការគឺ:

១.**បក្កមនន្តិកា** មានកិរិយាជៀសចេញ ចាកដែនកឋិនាវាសជាកំណត់ ។

២.**និដ្ឋានន្តិកា** មានកិរិយាធ្វើចីវរសម្រេចជាកំណត់ ។

៣.**សន្និដ្ឋានន្តិកា** មានសេចក្តីសន្និដ្ឋានសុកចិត្តព្រមជាកំណត់ ។

៤.**នាសនន្តិកា** មានចីវរវិនាសជាកំណត់ ។

៥.**សវនន្តិកា** មានកិរិយាឮដំណឹកជាកំណត់ ។

៦.**អាសាវច្ឆេទិកា** ដាច់សេចក្តីបំណងឬអស់សេចក្តីសង្ឃឹម ។

៧.**សីមាតិក្កន្តិកា** មានកិរិយាកន្លងខេត្តកឋិនជាកំណត់ ។

៨.**សហុព្ភារា** សង្ឃព្រមព្រៀងគ្នាសូត្រដោះកឋិន ។

**២១/សំនួរ ពលិពោធរបស់កឋិកមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ ?**

**ចម្លើយ** ពលិពោធរបស់កឋិនមាន២យ៉ាងគឺ:

១.**អាវាសពលិពោធោ** កង្វល់ក្នុងអាវាសគឺភិក្ខុក្នុងអាវាសនោះក្ដី មានសេចក្ដីអាល័យចំពោះអាវាសនោះហើយជៀសចេញទៅដោយបំណងថា អាត្មាអញ និងត្រឡប់វិញក្ដី ។

២.**ចីវរពលិពោធោ** កង្វល់ក្នុងចីវរ គឺចីវរដែលភិក្ខុមិនទាន់បានធ្វើ ឬបានធ្វើហើយតែមិនទាន់ស្រេចទាំងសេចក្ដីប្រាថ្នា ចីវរក៏មិនទាន់ដាច់នៅឡើយ ។

**២២/សំនួរ តើអនត្តតាការមានប៉ុន្មាន ? គឺអ្វីខ្លះ ?**

**ចម្លើយ** អនត្តតាការមាន ២៤ គឺ:

១.**ឧលិខិតមត្តេន** ក្រាលដោយសំពត់គ្រាន់តែវាសគូសក្រិតបំណាំ ។

២.**វធាវនមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែបោកគួកលាង ។

៣.**ចីវរវិចារណាមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែចាត់ចែងលៃលកធ្វើជាខណ្ឌ័មានបញ្ចខ័ណ្ឌជាដើម ។

៤.**ឆេទនមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែកាត់តាមបែបដែលបានចាត់ចែង ។

៥.**ពន្ធនមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែដានភ្ជាប់គ្នា។

៦.**ឱវដិកករណមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែដេរផ្ទេរវែងៗ ឬរង្វើលៗតាមជួរជើងចេសដែលដានផ្គុំ ។

៧.**កណ្ឌូសករណមត្តេន** ក្រាលដោយសំពត់គ្រាន់តែភ្ជាប់ក្ដុំនិងក្រវិលក្ដុំ ។

៨.**ទឡ្ហីកម្មករណមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែត្រួតសំពត់ពីរស្រទាប់ដេរបញ្ចូលគ្នាធ្វើជាមួយ ។

៩.**អនុវាតករណមត្តេន** ក្រាលដែលសំពត់ ដែលគ្រាន់តែលើកឡើងនូវអនុវាតខាងក្នុង (អនុវាតខាងបណ្ដោយ) ។

១០.**បរិភណ្ឌករណមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែលើកឡើងនូវអនុវាតខាងពោះ (អនុវាតខាងទទឹង) ។

១១.**ឱវត្តេយ្យករណមត្តេន** ក្រាលដោយសំពត់ដែលគ្រាន់តែជួបគ្នា ។

១២.**កម្ពលមទ្ទនមត្តេន** ក្រាលដោយសំពត់គ្រាន់តែជ្រលក់ម្ដង មានពណ៌ដូចក្អុកដំរី ឬដូចស្លឹកឈើទុំ (ពណ៌លឿងខ្ចី) ។

១៣.**និមិត្តកតេន** ក្រាលដោយសំពត់ដែលកើតឡើង ដោយសារភិក្ខុធ្វើនិមិត្តកម្មយ៉ាងនេះថា អាត្មាក្រាលកឋិនដោយនិយាយបញ្ចិតបញ្ចៀងឲ្យទាយក ឬធ្វើកាយវិការណាមួយឲ្យទាយក ។

១៤.**បរិកថាកតេន** ក្រាលដោយសំពត់ដែលកើតឡើងដោយសារភិក្ខុនិយាយបញ្ចុះបញ្ចូលយកយ៉ាងនេះថា ការប្រគេនសំពត់កឋិនគួរ ព្រោះទាយកអ្នកប្រគេនសំពត់កឋិន រមែងបានជួបប្រសព្វនិងបុណ្យយ៉ាងធំ ។

១៥.**កុក្កុកតេន** ក្រាលដោយសំពត់ខ្ចីគេ ឬសំពត់របស់ខ្លួន ។

១៦.**សន្និធិកតេន** ក្រាលដោយសំពត់ដែលមិនបានធ្វើឲ្យស្រេចក្នុងថ្ងៃនោះ ។

១៧.**និស្សគ្គិយេន** ក្រាលដោយសំពត់ដែលធ្វើឲ្យកន្លងរាត្រី ។

១៨.**អកប្បកតេន** ក្រាលដោយសំពត់មិនបានធ្វើពិន្ទុកប្ប ។

១៩.**អញ្ញត្រសង្ឃាដិយា** ក្រាលដោយសំពត់ឯទៀត ក្រៅពីសង្ឃាដី ។

២០.**អញ្ញត្រឧត្តរាសង្គេន** ក្រាលដោយសំពត់ឯទៀត ក្រៅពីឧត្តរាសង្គ ។

២១.**អញ្ញត្រអន្តរវាសកេន** ក្រាលដោយសំពត់ឯទៀតក្រៅពីអន្តរវាសក ។

២២.**អញ្ញត្រ បញ្ចកេនវា អតិរេក បញ្ចកេនវា តទហេវ សញ្ឆិន្នេន សមណ្ឌ លីកតេន** វៀរចាកចីវរមានមណ្ឌលគ្រប់គ្រាន់ ដែលកាត់ដាច់ជាបញ្ចខណ្ឌក្តី លើសពីបញ្ចខណ្ឌក្តី ក្នុងថ្ងៃនោះឯងហើយ

ក្រាល ។

២៣.**អញ្ញត្រ បុគ្គលស្ស អត្ថារា** មិនឲ្យបុគ្គលក្រាល ទៅឲ្យសង្ឃ ឬគណក្រៅវិញ ។

២៤.**និស្សីមដ្ឋោ អនុមោទត្តិ** ភិក្ខុស្ថិតនៅក្រៅ ឧបចារសីមាដែលជាខេត្ត ភិក្ខុចូលវស្សា ក្រាលអនុមោទនាកឋិន ។

**២៣/សំនួរ តើអត្ថតាការៈមានប៉ុន្មាន ? គឺអ្វីខ្លះ ?**

**ចម្លើយ** អត្ថតាការៈមាន១៧គឺ:

១.**អហតេន** ក្រាលដោយសំពត់ថ្មី ។

២.**អហតកប្បេន** ក្រាលដោយសំពត់ជំនំ ។

៣.**បិលោតិកាយ** ក្រាលដោយសំពត់ចាស់ ។

៤.**បំសុកូលេន** ក្រាលដោយសំពត់បង្សុកូល ។

៥.**អាបណិកេន** ក្រាលដោយសំពត់ធ្លាក់ទៀបរានផ្សារ ។

៦.**អនិមិត្តកតេន** ក្រាលដោយសំពត់ដែលកើតឡើងដោយមិនបានធ្វើនិមិត្តកម្ម ។

៧.**អបរិកថាកតេន** ក្រាលដោយសំពត់ដែលកើតឡើងដោយមិនបាននិយាយបញ្ចុះបញ្ចូល ។

៨.**អកុក្កកតេន** ក្រាលដោយសំពត់ដែលមិនខ្ចីគេ ។

៩.**អសន្និធិកតេន** ក្រាលដោយសំពត់ដែលបានធ្វើឲ្យស្រេច

ក្នុងថ្ងៃនោះ ។

១០.**អនិស្សត្ថិយេន** ក្រាលដោយសំពត់ដែលមិនធ្វើឲ្យកន្ទង់រាត្រី ។

១១. **កប្បកតេន** ក្រាលដោយសំពត់ដែលបានធ្វើពិន្ទុកប្ប ។

១២.**សង្ឃាដិយា** ក្រាលដោយសង្ឃាដី ។

១៣.**ឧត្តរាសង្គេន** ក្រាលដោយឧត្តរាសង្គ ។

១៤.**អន្តរវាសកេន** ក្រាលដោយអន្តរវាសក ។

១៥.**បញ្ចកេនវា អតិរេក បញ្ចកេន វា តទហេវ សញ្ឆិន្នេន សមណ្ឌលិកតេន** ក្រាលដោយចីវរមានមណ្ឌលគ្រប់គ្រាប់ ដែលកាត់ដាច់ជាបញ្ចខណ្ឌក្តី លើសពីបញ្ចខណ្ឌក្តី ក្នុងថ្ងៃនោះឯង ។

១៦.**បុគ្គលស្ស អត្ថារា** ក្រាលដោយកិរិយាក្រាលរបស់បុគ្គល។

១៧.**សីមដ្ឋោ អនុមោទតិ** ភិក្ខុស្ថិតនៅក្នុងឧបចារសីមាក្រាលអនុមោទនាកឋិន ។

**២៤/សំនួរ វិន័យរបស់សាមណេរមានប៉ុន្មាន ? អ្វីខ្លះ ? វិន័យរបស់ភិក្ខុមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** វិន័យរបស់សាមណេរមាន៣០គឺ សិក្ខាបទ១០,ទណ្ឌកម្ម១០ និងនាសនង្គ ១០។ ចំណែកខាងវិន័យរបស់ភិក្ខុមាន ២២០

បើរាប់ទាំងអធិករណសមថ ៧ ផង ត្រូវជា ២២៧ ។

**២៥/សំនួរ ទណ្ឌកម្មគឺអ្វី ? មានប៉ុន្មាន ? សាមណេរត្រូវទណ្ឌកម្មហើយ តើត្រូវឲ្យឧបជ្ឈាយ៍ធ្វើយ៉ាងណា ?**

**ចម្លើយ** ទណ្ឌកម្មគឺទោស កំហុសដែលសាមណេរប្រព្រឹត្តខុស ហើយមាន ១០ យ៉ាង ។ សាមណេរត្រូវទោសទណ្ឌកម្មហើយ ព្រះឧបជ្ឈាយ៍ត្រូវធ្វើទោស មានឲ្យបោសសំអាតទីវត្តអារាម ដោយមានកំរិតធ្ងន់ជាដើម ។

**២៦/សំនួរ ពេលថ្ងៃជ្រេរទៅហើយ សាមណេរសឹងលក់ មានគេយកបាយទៅបញ្ចុក សាមណេរក៏លេបចូលទៅផុតបំពង់កទៅ តើត្រូវទោសអ្វី ? ចូរទាញហេតុផលមកអាង ?**

**ចម្លើយ** ត្រូវទណ្ឌកម្មព្រោះវិកាលភោជននេះលោកកំណត់ជាឲ្យតែលេបផុតពីបំពង់កទៅហើយ សុទ្ធតែត្រូវទោសទាំងអស់ទោះមានចិត្តប៉ងក្តី គ្មានក្តី ។

**២៧/សំនួរ អាបត្តិមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់ហើយពន្យល់ ។**

**ចម្លើយ** អាបត្តិមានច្រើនយ៉ាង តែបើនិយាយឲ្យខ្លីមក មានតែ ២យ៉ាងគឺ:

ក.**គរុកាបត្តិ** អាបត្តិដែលមានទោសធ្ងន់ កាលភិក្ខុត្រូវហើយ

ត្រូវតែលាចាកភេទមានបារាជិក៤ជាដើម ឬក៏សង្ឃត្រូវទោសយ៉ាងធ្ងន់ បានដល់សង្ឃាទិសេស១៣ ។

២.លហុកាបត្តិ អាបត្តិដែលមានទោសស្រាលកាលភិក្ខុត្រូវហើយ គ្រាន់តែសម្តែងប្រាប់ទោសដល់សង្ឃជាការស្រេច ។

**២៨/សំនួរ ពាក្យថា សិក្ខា និងសិក្ខាបទ ដូចគ្នាឬផ្សេងគ្នា ? ចូរពន្យល់ឲ្យល្មមស្តាប់បាន ?**

**ចម្លើយ** ពាក្យថា សិក្ខា និងសិក្ខាបទផ្សេងគ្នាគឺ សិក្ខាបានដល់ការសិក្សាធម៌វិន័យទូទៅ ដូចជាត្រៃសិក្ខា មានសីលជាដើម។ សិក្ខាកាមបំណងប៉ងប្រាថ្នាក្នុងការសិក្ខា ។ សិក្ខានេះមានន័យទូលំទូលាយជាងសិក្ខាបទ ។

ចំណែកខាងសិក្ខាបទវិញ បានដល់បទបញ្ញត្តិ ដែលព្រះសម្ពុទ្ធទ្រង់ហាមប្រាមទាំងអស់ ដូចជាសិក្ខាបទ ១០ របស់សាមណេរ ឬសិក្ខាបទ ២២០ របស់ភិក្ខុជាដើម ។ សិក្ខាបទនេះមានន័យចង្អៀតតូចជាងពាក្យថាសិក្ខា ។

**២៩/សំនួរ ពាក្យថា វិន័យ និងសីល ដូចគ្នា ឬផ្សេងគ្នា ? បើផ្សេងគ្នា តើមានសេចក្តីពន្យល់យ៉ាងណា ?**

**ចម្លើយ** ពាក្យថា វិន័យនិងសីលផ្សេងគ្នាគឺៈ

វិន័យ បានដល់បទបញ្ញត្តិ និងពុទ្ធានុញ្ញាតទាំងអស់រាប់ពី

សិក្ខាបទជាដើម រហូតទៅដល់ពុទ្ធានុញ្ញាតមានកឋិនកម្មជាទីបំផុត។ វិន័យនេះ គឺជាគោលច្បាប់សម្រាប់ព្រះសង្ឃពុទ្ធសាសិកគោរពប្រតិបត្តិតាមដើម្បីឲ្យមានរបៀបរៀបរយ ។

ចំណែកខាងសីលវិញ បានដល់វិរតិចេតនាគឺការតាំងចិត្តវៀរចាកតាមសិក្ខាបទបញ្ញត្តិដែលជាវិន័យនោះឡើង ។ ការកាន់តាមវិន័យនេះហើយ ដែលអាចនាំឲ្យសីលកើតឡើង ។ ដូច្នេះវិន័យ និងសីលមានន័យផ្សេងគ្នា ប៉ុន្តែមានការអាស្រ័យទាក់ទងគ្នាជាការចាំបាច់កាលណាមានន័យ និងអាចមានសីលបាន ។

**៣០/សំនួរ ភិក្ខុកាលត្រូវអាបត្តិបារាជិកហើយ ត្រូវតែមានទោសឲ្យស្ថិតនៅក្រៅភេទជាអ្នកបួស ប៉ុន្តែបើអ្នកនោះចង់បួសវិញ តើអាចបួសបានឬទេព្រោះអ្វី? ចូរពន្យល់?**

**ចម្លើយ** បុគ្គលអ្នកត្រូវបារាជិកហើយ ត្រូវតែដាច់សំវាសពីព្រះសង្ឃ ជាការចាំបាច់ ទោះជាបុគ្គលនោះមានប្រាថ្នាចង់បួសវិញក៏មិនអាចបួសជាភិក្ខុវិញបានដែរ បើប្រព្រឹត្តិឲ្យតឹងរឹង ហើយបួសជាសាមណេរវិញបាន ឬកាន់សីល១០ សីល៨ ក៏បាន ។ ទោសបារាជិករបស់បុគ្គលនោះអាចឃាត់តែស្ថាននិព្វានក្នុង១ជាតិនោះតែប៉ុណ្ណោះ តែមិនឃាត់ស្ថានសួគ៌បានឡើយ ។ បើបុគ្គលនោះ ប្រព្រឹត្តឲ្យល្អតទៅមុខទៀត នឹងអាចសម្រេចស្ថាននិព្វានបន្ទាប់ពីជាតិនោះបាន ។

**៣១/សំនួរ សិក្ខាបទមាន ១០ បើសាមណេរប្រព្រឹត្តខុសនិង សិក្ខាបទ៥ខាងដើម តើត្រូវមានទោសអ្វី ? ៥ ខាងចុង តើត្រូវទោស អ្វី ? អ្នកត្រូវទោសទាំងពីរ តើត្រូវធ្វើទោសយ៉ាងណា ? ចូរពន្យល់ ?**

**ចម្លើយ** ក្នុងសិក្ខាបទទាំង១០ របស់សាមណេរនោះ បើសាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទ ៥ ខាងដើមសិក្ខាបទណា១ ត្រូវមានទោសនាសនង្គ ឧបជ្ឈាយ៍ ឬអាចារ្យត្រូវផ្សឹកចេញ ។

បើសាមណេរប្រព្រឹត្តខុស និងសិក្ខាបទ៥ខាងចុង សិក្ខាបទណា១ ត្រូវមានទោសត្រឹមទណ្ឌកម្មប៉ុណ្ណោះ ហើយឧបជ្ឈាយ៍ ឬអាចារ្យ គ្រាន់តែធ្វើទោស មានឲ្យរែកទឹក ស្រោចច្បារ ឬដាក់ពាងជាដើម ។

**៣២/សំនួរ សាមណេរនិងភិក្ខុត្រូវគំនិតគ្នា ក៏សម្លាប់មនុស្ស ម្នាក់ចោលដោយចេតនា ។ តើអ្នកទាំងពីរត្រូវទទួលដូចគ្នា ឬផ្សេង គ្នា ? បើផ្សេងគ្នា តើផ្សេងយ៉ាងណា ?**

**ចម្លើយ** សាមណេរនិងភិក្ខុរួមគ្នាសម្លាប់មនុស្ស ឲ្យស្លាប់បាត់បង់ជីវិត ត្រូវមានទោសផ្សេងគ្នា គឺសាមណេរត្រូវនាសនង្គៈ ត្រូវផុតភាពពីសាមណេរតែអាចបួសវិញជាសាមណេរបាន បើមានអាយុគ្រប់២០ឆ្នាំ ហើយអាចបួសជាភិក្ខុបានទៀត ។ ចំណែកខាងភិក្ខុ ត្រូវដាច់ផុតសង្វាសពីសង្ឃហើយត្រូវសឹកចេញ បើនឹងបួសជាភិក្ខុវិញមិនបានទេ បួសបានត្រឹមតែសាមណេរ តែត្រូវមានការ ប្រព្រឹត្តធ្ងន់

ណាស់ ។

**៣៣/សំនួរ សីលរបស់ភិក្ខុមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** សីលរបស់ភិក្ខុមាន៤យ៉ាងគឺ

ក.**បាតិមោក្ខសំវរសីល** ការសង្រួមដោយល្អ ក្នុងបាតិមោក្ខ ។

ខ.**ឥន្ទ្រីយសំវរសីល** ការសង្រួមក្នុងឥន្ទ្រីយ ។

គ.**អាជីវបារិសុទ្ធិសីល** ការចិញ្ចឹមជីវិតឲ្យបរិសុទ្ធ ។

ឃ.**បច្ច័យសន្និស្សិតសីល** សីលគឺការអាស្រ័យនូវបច្ច័យ៤ ។

**៣៤/សំនួរ ពាក្យថា អាបត្តិ មានន័យសេចក្ដីដូចម្ដេច ? អាបត្តិមានសមុដ្ឋានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** ពាក្យថា អាបត្តិបានសេចក្ដីថា ការដល់,ការត្រូវ,ការធ្លាក់ចុះ គឺដល់នូវសេចក្ដីវិនាស, ត្រូវទោស,ការធ្លាក់ចុះក្នុងអន្តរាយ ។ អាបត្តិនេះមានមានសមុដ្ឋាន៦យ៉ាងគឺ:

ក.**កាយ** អាបត្តិកើតឡើងពីកាយ ។

ខ.**វាចា** អាបត្តិកើតឡើងពីវាចា ។

គ.**កាយវាចា** អាបត្តិកើតឡើងពីកាយវាចា ។

ឃ.**កាយចិត្ត** អាបត្តិកើតឡើងពីកាយចិត្ត ។

ង.**វាចាចិត្ត** អាបត្តិកើតឡើងពីវាចាចិត្ត ។

ច.**កាយវាចាចិត្ត** អាបត្តិកើតឡើងពីកាយវាចាចិត្ត ។

សមុដ្ឋានទាំង៦នេះ ខ្លះមានអង្គ១ ដូចទី១ និងទី២,ខ្លះមានអង្គ២ ដូចត្រង់ទី៣ ទី៤និងទី៥,ខ្លះមានអង្គ៣ ដូចត្រង់ទី៦ ។ សមុដ្ឋានទី១,២,៣ ជាអចិត្តកសមុដ្ឋាន ព្រោះគ្មានចិត្តលាយឡំ ។

អាបត្តិខ្លះ កើតដោយសមុដ្ឋាន១ក៏មាន,២ក៏មាន ៣ក៏មាន, ៤ក៏មាន,៦ក៏មាន តែគ្មានកើតឡើងដោយសមុដ្ឋាន៥ទេ ។ អាបត្តិទាំងអស់គ្មានកើតឡើងដោយចិត្តឡើយ ។

**៣៥/សំនួរ ភិក្ខុនិងសាមណេររួមគ្នាសម្លាប់សត្វកណ្តុរមួយឲ្យបាត់បង់ជីវិត តើមានទោសដូចម្តេច ? ចូរពន្យល់ ?**

**ចម្លើយ** ភិក្ខុនិងសាមណេររួមគ្នាសម្លាប់សត្វកណ្តុរមួយ ឲ្យស្លាប់ភិក្ខុត្រូវអាបត្តិបាចិត្តិយ គ្រាន់តែសម្តែងប្រាប់សង្ឃ និងអាចរួចចាកទោសនោះបាន,ចំណែកសាមណេរវិញ ត្រូវផុតពីសាមណេរភាព តែអាចបួសជាសាមណេរ ឬបំពេញឧបសម្បទាបាន ។

**៣៦/សំនួរ វិន័យគឺអ្វី ? មានគោលប៉ុន្មានផ្នែក ? អ្វីខ្លះ ? ចូររាប់និងអត្ថាធិប្បាយ ?**

**ចម្លើយ** វិន័យគឺជាច្បាប់ជាពុទ្ធប្បវេណី ដែលព្រះអង្គបានតាំងទុកដើម្បីរៀបចំគ្រប់គ្រងមានសណ្តាប់ធ្នាប់ល្អ ។ វិន័យនេះគោល៣ផ្នែកគឺ បញ្ញត្តិ១ អនុញ្ញាត១ អភិសមាចារ១ ។ បញ្ញត្តិគឺខដែលព្រះពុទ្ធអង្គទ្រង់ហាមមិនឲ្យសង្ឃ សាវ័កប្រព្រឹត្តធ្វើពាយផាយ

តាមអំពើចិត្តព្រមទាំងប្រាប់ទោសធ្ងន់ស្រាលផង ។ អនុញ្ញាតគឺខ ដែលព្រះពុទ្ធអង្គទ្រង់យល់ព្រមឲ្យធ្វើ ។ អភិសមាចារ ការប្រព្រឹត្ត រៀបរយល្អ ឬកិច្ចដែលបព្វជិត ត្រូវបំពេញ ប្រព្រឹត្តឲ្យបរិបូណ៌ ។

***៣៧/សំនួរ អាបត្តិខ្វះ កាលភិក្ខុប្រព្រឹត្តធ្វើក៏ត្រូវទោស តែខ្វះ មិនប្រព្រឹត្តធ្វើក៏ត្រូវទោសដែរ តើអាបត្តិទាំងពីរនេះប្លែកគ្នាយ៉ាង ណា ? ចូររកកងអាបត្តិខ្វះមកអាង ។***

***ចម្លើយ*** អាបត្តិដែលកើតឡើងដោយកាយ ឬដោយវាចា ហៅ ថា អាបត្តិជាកិរិយា គឺភិក្ខុបានប្រព្រឹត្តធ្វើឲ្យកន្ទង និងត្រូវទោសដូច ជាបឋវី សិក្ខាបទជាដើម ។

អាបត្តិដែលកើតឡើងដល់ភិក្ខុអ្នកមិនធ្វើនូវអំពើ ដែលត្រូវធ្វើ ដោយកាយនិងវាចាឈ្មោះថា អាបត្តិជាអកិរិយាដូចបឋមកឋិន សិក្ខា បទជាដើម ។

***៣៨/សំនួរ អាការៈដែលភិក្ខុត្រូវអាបត្តិ មានប៉ុន្មានយ៉ាង ? អ្វីខ្វះ ? ចូររាប់ដោយខ្វី ?***

***ចម្លើយ*** អាការៈដែលភិក្ខុត្រូវអាបត្តិ ហៅថា អាបត្តិបដ្ឋនាការ មាន៦យ៉ាងគឺ:

ក.***អលជ្ជិតា*** អាការៈមិនមានខ្មាស ។

ខ.***អញ្ញាណតា*** អាការៈមិនស្គាប់អាបត្តិ ។

គ.**កុក្កុច្ចប្បកតត្តា** អាការៈសង្ស័យហើយចេះតែធ្វើ ឬអាការៈបំពានសេចក្តីសង្ស័យ ។

ឃ.**អកប្បិយេ កប្បិយសញ្ញិតា** អាការៈសម្គាល់ផ្ទុយថា គួរក្នុងរបស់ដែលមិនគួរ ។

ង.**កប្បិយេ អកប្បិយសញ្ញិតា** អាការៈសម្គាល់ផ្ទុយថាមិនគួរក្នុងរបស់ដែលគួរ ។

ច.**សតិសម្មោសា** អាការៈដែលភ្លេចស្មារតី ។

**៣៩/សំនួរ លោកវជ្ជសិក្ខាបទគឺអ្វី ? មានប៉ុន្មានយ៉ាង ? សាមណេរក្មេងទឹកអសុចិ ឲ្យកម្រើកឃ្លាតចាកទីនិងសាមណេរមានតម្រេកចាប់ត្រូវកាយស្ត្រី តើត្រូវទោសអ្វី ? មានក្នុងសិក្ខាបទណា ? ចុះបើភិក្ខុធ្វើដូច្នោះវិញ តើត្រូវទោសអ្វីដែរ ?**

**ចម្លើយ** លោកវជ្ជសិក្ខាបទ គឺសិក្ខាបទដែលអ្នកប្រព្រឹត្តខុសហើយទទួលទោសក្នុងលោកនេះឯង ។ សិក្ខាបទពួកនេះមានចំនួន ៤៩ ។ បើសាមណេរក្មេងធ្វើទឹកអសុចិឲ្យកម្រើកឃ្លាតចាកទី និងសាមណេរមានតម្រេកចាប់ពាល់ត្រូវកាយស្ត្រី ត្រូវទោសទណ្ឌកម្ម ដែលមានក្នុងលោកវជ្ជសិក្ខាបទត្រង់សុក្កវិសដ្ឋិនិងកាយសំសគ្គ ។ សិក្ខាបទនេះ បើភិក្ខុប្រព្រឹត្តធ្វើឲ្យកន្លងវិញត្រូវអាបត្តិសង្ឃាទិសេស។

**៤០/សំនួរ សាមណេរព្យាយាមបំបែកសង្ឃឲ្យបែកគ្នាហើយ**

**មានភិក្ខុហាមដែរ តែមិនព្រមស្តាប់ តើត្រូវទោសអ្វី ? មាននៅក្នុងសិក្ខាបទណា ? បើសាមណេរជេរសង្ឃវិញ តើត្រូវទោសអ្វី ? ហើយបើភិក្ខុព្យាយាមបំបែកសង្ឃរួចសង្ឃក៏បែកគ្នា តើត្រូវទោសអ្វីដែរ ?**

**ចម្លើយ** សាមណេរព្យាយាមបំបែកសង្ឃឲ្យបែកគ្នា ហើយភិក្ខុហាមដែរ តែមិនព្រមស្តាប់ ត្រូវទោសទណ្ឌកម្ម មាននៅក្នុងលោកវជ្ជសិក្ខាបទ ត្រង់សង្ឃភេទ ។ បើសាមណេរជេរសង្ឃ ត្រូវមានទោសនាសនង្គ ។ បើភិក្ខុព្យាយាមបំបែកសង្ឃរួចសង្ឃក៏បែកគ្នា ត្រូវអាបត្តិសង្ឃាទិសេស ។

**៤១/សំនួរ អាបត្តិទាំងអស់ បើចែកទៅតាមសញ្ញា តើមានប៉ុន្មានពួក ? អ្វីខ្លះ ? ចូររាប់ហើយពន្យល់ឲ្យស្តាប់បាន ?**

**ចម្លើយ** អាបត្តិទាំងអស់ បើចែកទៅតាមសញ្ញាមាន២ពួកគឺ សញ្ញាវិមោក្ខ=អាបត្តិដែលភិក្ខុអាចរួចខ្លួនដោយសញ្ញា១,នោ សញ្ញាវិមោក្ខ=អាបត្តិដែលភិក្ខុមិនអាចរួចខ្លួនដោយសញ្ញា១ ។

អាបត្តិពួកណាដែលភិក្ខុ អាចរួចខ្លួនដោយមិនមានសញ្ញាគឺ សេចក្តីស្គាល់ក្នុងការប្រព្រឹត្តល្មើសអាបត្តិពួកនេះហៅថា សញ្ញាវិមោក្ខ ដូចជាអាបត្តិក្នុងបឋមបារាជិកជាដើម គឺភិក្ខុមានសេវនចិត្តផ្តល់មគ្គនិងមគ្គឲ្យដល់គ្នា ត្រូវបារាជិក តែបើគ្មានសេវនចិត្តទេ គឺគ្មាន សញ្ញាក្នុងការសេពមិនត្រូវអាបត្តិឡើយ ។ នេះហៅថា សញ្ញា

វិមោក្ខ។

អាបត្តិពួកណាដែលភិក្ខុមិនរួចខ្លួន ដោយមិនសញ្ញាក្នុងការប្រព្រឹត្តល្មើស ដូចជាអាបត្តិក្នុងសញ្ចរិតសិក្ខាបទជាដើម អាបត្តិពួកនេះឈ្មោះថា នោ សញ្ញាវិមោក្ខ ។

**៤២/សំនួរ ចុះបើចែកទៅតាមចិត្តវិញ តើមានប៉ុន្មានដែរ ? អ្វីខ្លះ ? ចូររាប់និងពន្យល់ ?**

**ចម្លើយ** អាបត្តិទាំងអស់ បើចែកតាមចិត្តវិញ ក៏មាន២ពួកដែរ គឺ សចិត្តកា=អាបត្តិប្រកបដោយចិត្ត១,អចិត្តកា=អាបត្តិមិនប្រកបដោយចិត្ត១ ។

អាបត្តិពួកណាតែងកើតឡើងដោយសចិត្តកសមុដ្ឋានសុទ្ធ ដូចជាអាបត្តិក្នុងបឋមបារាជិកសិក្ខាបទជាដើម អាបត្តិពួកនេះឈ្មោះថា សចិត្តកា ។

អាបត្តិពួកណាកើតដោយអចិត្តកសមុដ្ឋានផង ដោយសចិត្តកមស្សកសមុដ្ឋានផង ដូចជាអាបត្តិក្នុងសញ្ចរិត្តសិក្ខាបទជាដើម អាបត្តិពួកនេះឈ្មោះថា អចិត្តកា ។

**៤៣/សំនួរ ភិក្ខុនិងសាមណេរ មានចិត្តតម្រេកបានទៅនិយាយល្បួងលួងលោមស្ត្រីឲ្យបម្រើខ្លួនដោយកាម តើត្រូវទោសអ្វី ? អ្នកណាធ្ងន់ជាងអ្នកណា ?**

**ចម្លើយ** ភិក្ខុនិងសាមណេរ មានចិត្តតម្រេកបានទៅនិយាយល្បួងលួងលោមស្ត្រីឲ្យបម្រើខ្លួនដោយកាមត្រូវមានទោសយ៉ាងនេះគឺ:

ក.ភិក្ខុត្រូវអាបត្តិសង្ឃាទិសេសពេញទី ។

ខ.សាមណេរត្រូវត្រឹមទោសទណ្ឌកម្មប៉ុណ្ណោះ ។ អ្នកទាំងពីនេះ ភិក្ខុត្រូវទោសធ្ងន់ជាងសាមណេរ ។

**៤៨/សំនួរ សាមណេរបានចូលដៃជើងជាមួយភិក្ខុឆ្គួត ទៅលួចទ្រព្យអ្នកដទៃបានមក តើសាមណេរនោះត្រូវទោសអ្វី ? ភិក្ខុត្រូវទោសអ្វី ? ព្រោះអ្វី ?**

**ចម្លើយ** សាមណេរបានចូលដៃជាមួយភិក្ខុឆ្គួត ទៅលួចទ្រព្យគេបានមក សាមណេរនោះត្រូវទោសនាសនង្គពេញទី ឯភិក្ខុវិញឥតត្រូវទោសអ្វីទេ ព្រោះខ្លួនឆ្គួត ។

**៤៩/សំនួរ អាបត្តិភិក្ខុអទិន្នាទានសិក្ខាបទ តើមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** អាបត្តិភិក្ខុក្នុងអទិន្នាទានសិក្ខាបទមាន ៣ ពួកគឺ:

ក.ត្រូវបារាជិក ដោយការលួចរបស់មានតម្លៃតាំងពី៥ មាសកឡើងទៅ ។

ខ.ត្រូវអាបត្តិថុល្លច្ច័យ ដោយការលួចរបស់មានតម្លៃតិចជាង

៥មាសក ។

គ.ត្រូវអាបត្តិទុក្កដ ការលួចរបស់ខ្លះពីមួយមាសក ។

**៤៦/សំនួរ អាបត្តិទាំងអស់ បើចែកតាមប្រភេទនៃកម្ម មានប៉ុន្មានពួក ? អ្វីខ្លះ ? ចូររាប់និងពន្យល់ ? ចុះចែកតាមប្រភេទនៃវិជ្ជវិញ តើមានប៉ុន្មាន ? អ្វីខ្លះ ? ចូររាប់និងពន្យល់ផង ?**

**ចម្លើយ** អាបត្តិទាំងអស់ បើចែកតាមប្រភេទនៃកម្មមាន ៣ ពួកគឺ:

ក.**កាយកម្ម** អាបត្តិជាកាយកម្មប្រព្រឹត្តទៅក្នុងកាយទ្វារ ដូចជា អាបត្តិក្នុងបារាជិកជាដើម ។

ខ.**វចីកម្ម** អាបត្តិជាវចីកម្ម ប្រព្រឹត្តទៅក្នុងកាយទ្វារ ដូចជាអាបត្តិក្នុងបទសោធម្មសិក្ខាបទជាដើម ។

គ.**តទុភយកម្ម** អាបត្តិជាកម្មទាំងពីរប្រព្រឹត្តទៅក្នុងកាយកម្ម វចីកម្ម ដូចជាអាបត្តិក្នុងអទិន្នាទានាសិក្ខាបទជាដើម ។

អាបត្តិទាំងអស់បើចែកតាមប្រភេទនៃវជ្ជមាន ២ ពួកគឺ:

ក.**លោកវជ្ជ** អាបត្តិមានទោសតាមផ្លូវលោក ដូចជាអាបត្តិក្នុងបឋមបារាជិកជាដើម ។

ខ.**បណ្ណត្តិវជ្ជ** អាបត្តិមានទោសក្នុងពុទ្ធប្បញ្ញត្តិ ដូចជាអាបត្តិក្នុងសញ្ចរិតសិក្ខាបទជាដើម ។

**៤៧/សំនួរ ភិក្ខុក្រោធខឹងនឹងភិក្ខុដទៃ ហើយក្លែងចោទដោយអាបត្តិបារាជិក ដោយមិនមានមូល តើត្រូវទោសអ្វី ? មាននៅក្នុង ណា ? ចុះបើសាមណេរប្រព្រឹត្តដូច្នោះវិញ តើត្រូវទោសអ្វី ? មាននៅក្នុងណា ?**

**ចម្លើយ** ត្រូវសង្ឃាទិសេស មាននៅក្នុងកងអាបត្តិសង្ឃាទិសេស ត្រង់អមូលក ។ បើសាមណេរប្រព្រឹត្តដូច្នេះវិញ នឹងត្រូវទោសទណ្ឌកម្មមាន នៅក្នុងលោកវជ្ជសិក្ខាបទត្រង់អមូលកដែរ ។

**៤៨/សំនួរ ភិក្ខុនិងសាមណេរ និយាយកុហកដោយចេតនាដូចគ្នា តើត្រូវទោសអ្វី ?**

**ចម្លើយ** ភិក្ខុនិងសាមណេរ និយាយកុហកដោយអចេតនាដូចគ្នា ភិក្ខុត្រូវអាបត្តិបាចិត្តិយ ឯសាមណេរវិញត្រូវនាសនង្គ ។

**៤៩/សំនួរ អនាបត្តិកភិក្ខុក្នុងអទិន្នាទានសិក្ខាបទមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** អនាបត្តិកភិក្ខុ ក្នុងអទិន្នាទានសិក្ខាបទមាន ៨ ពួកគឺ:

ក.កាន់យកដោយសម្គាល់ថាជារបស់ខ្លួន ។

ខ.កាន់យកដោយសេចក្តីស្និទ្ធស្នាលនឹងគ្នា ។

គ.កាន់យកជារបស់ខ្ចីគ្នា ។

ឃ.កាន់យករបស់ដែលពួកប្រេតថែរក្សា ។

ង.កាន់យកដោយសម្គាល់ថាជារបស់បង្សុកូល ។

ច.ភិក្ខុច្ឆត ។

ឆ.ភិក្ខុដើមបញ្ញត្តិ ។

**៩០/សំនួរ ភិក្ខុនិងសាមណេរជាបងប្អូនគ្នា បានចាប់លើកញោមស្រីដែលមានជំងឺ តើត្រូវទោសអ្វីដែរ ?**

**ចម្លើយ** ភិក្ខុនិងសាមណេរជាបងប្អូនគ្នា បានចាប់លើកញោមស្រីដែលមានជំងឺ គ្មានត្រូវទោសអ្វីទេ ។

**៩១/សំនួរ វិន័យឲ្យទោសដូចម្តេចខ្លះ ដល់អ្នកដែលប្រតិបត្តិមិនល្អ ? ចូរអធិប្បាយ ?**

**ចម្លើយ** វិន័យឲ្យទោសអ្នកប្រតិបត្តិមិនល្អយ៉ាងនេះគឺ:

.ត្រូវឃ្លាតចាកភេទពីអ្នកបួស ។

.ប្រាសចាកពីសង្ឃសំវាស ។

.ទទួលអាម៉ាស់មុខនៅកណ្តាលជំនុំសង្ឃ និងចំពោះសាធារណជន ។

**៩២/សំនួរ ហេតុដូចម្តេចបានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា វិន័យជាឫសគល់នៃព្រះពុទ្ធសាសនា ? ចូរអធិប្បាយ ?**

**ចម្លើយ** បានជាព្រះសម្ពុទ្ធទ្រង់ត្រាស់ថា វិន័យជាឫសគល់នៃព្រះពុទ្ធសាសនា ព្រោះវិន័យនេះទុកដូចជាឫសកែវនៃឈើ១ដើម បើ

កាលណាកែវនៃឈើនោះដាច់ឬពុកឬក៏មានសត្វស៊ីអស់ហើយ ដើមឈើនោះក៏និងដាប់ទៅភ្លាម ប្រសិនបើនៅរស់វិញ ក៏មិនងាយនិងជាប់រឹងពឹងបានឡើយ ។

ចំណែកខាងព្រះពុទ្ធសាសនាវិញ បើគ្មានអ្នកប្រតិបត្តិវិន័យទេ ព្រះវិន័យក៏ត្រូវសាបសូន្យ ព្រះពុទ្ធសាសនា ក៏ត្រូវសាបសូន្យដែរ ព្រោះវិន័យជាឫសកែវនៃព្រះពុទ្ធសាសនា ។ ម្យ៉ាងទៀតក្នុងចំណោមព្រះត្រៃបិដកទាំង៣ បើព្រះសូត្រឬ ព្រះអភិធម្មវិនាសសាបសូន្យទៅ ដោយគ្មានអ្នកទ្រទ្រង់ ហើយនៅតែព្រះវិន័យមានអ្នកប្រតិបត្តិព្រះពុទ្ធសាសនាក៏អាចនៅគង់វង់បានដែរ ។ ផ្ទុយទៅវិញបើព្រះសូត្រ និងព្រះអភិធម្មនៅគង់វង់ តែព្រះវិន័យវិនាសសាបសូន្យទៅព្រះពុទ្ធសាសនាក៏គង់មិននៅគង់វង់ ឬរុងរឿងកើតឡើយ ។

**៨៣/សំនួរ សាមណេរមានជាតិជាអ្នកបឹងរឹងរូស ប្រដៅក្រភិក្ខុឯទៀតហាមមិនស្តាប់ និងសាមណេរទ្រុស្តត្រកូល គឺសាមណេរដែលប្រចុបប្រចែង ផ្គាប់ផ្គន់គ្រហស្ថ សង្ឃបានបណ្តេញចេញអំពីវត្ត តើត្រូវទោសអ្វី? បើភិក្ខុប្រព្រឹត្តដូច្នេះវិញ តើត្រូវទោសអ្វី?**

**ចម្លើយ** សាមណេរប្រព្រឹត្តដូច្នេះនិងត្រូវទោសត្រឹមទណ្ឌកម្មប៉ុណ្ណោះ ។

ផ្ទុយទៅវិញ បើភិក្ខុប្រព្រឹត្តដូច្នេះវិញ នឹងត្រូវអាបត្តិសង្ឃាទិ

សេសពេញទី ។

**៩៤/សំនួរ ភិក្ខុបង្គាប់សាមណេរឲ្យសេពមេថុនធម្ម តើភិក្ខុនោះត្រូវទោសអ្វី ឯសាមណេរដែលបានសេពដោយចិត្តត្រេកអរដែរ តើភិក្ខុត្រូវទោសអ្វី?**

**ចម្លើយ** ភិក្ខុអ្នកបង្គាប់នោះ គ្មានទោសអ្វីឡើយ ចំណែកខាងសាមណេរដែលបានសេពមេថុនធម្ម ដោយចិត្តត្រេកអរ ត្រូវទោសនាសនង្គ ។

**៩៥/សំនួរ អាបត្តិកភិក្ខុ ក្នុងមេថុនធម្មសិក្ខាបទ មានប៉ុន្មាន ? អ្វីខ្លះ? ចូររាប់?**

**ចម្លើយ** អាបត្តិកភិក្ខុ ក្នុងមេថុនធម្មសិក្ខាបទ មាន៣យ៉ាងគឺ:

ក.ត្រូវបារាជិកព្រោះសេពមេថុនធម្ម ក្នុងសរីរៈដែលសត្វមិនទាន់ស៊ី ។

ខ.ត្រូវអាបត្តិថុល្លច្ច័យ ព្រោះសេពមេថុនធម្ម ចំពោះសរីរៈដែលសត្វស៊ីអស់ច្រើនអន្លើ ។

គ.ត្រូវអាបត្តិទុក្កដ ដោយបានបញ្ចូលអង្គជាតិទៅក្នុងមាត់ដែលបើក តែមិនប៉ះត្រូវមាត់នោះ ។

**៩៦/សំនួរ តើអកប្បិយមំស ដែលព្រះ សម្ពុទ្ធទ្រង់ហាមមិនឲ្យភិក្ខុ សាមណេរឆាន់សាច់ មានប៉ុន្មានយ៉ាង?**

**ចម្លើយ** អកប្បិយមំស ១០ យ៉ាង ដែលព្រះសម្ពុទ្ធទ្រង់ហាមមិនឲ្យភិក្ខុ សាមណេរឆាន់សាច់ ១០ យ៉ាងគឺៈ

១.**មនុស្សមំស** សាច់មនុស្ស

២.**ហត្ថិមំស** សាច់ដំរី

៣.**អស្សមំស** សាច់សេះ

៤.**សុនខមំស** សាច់ឆ្កែ

៥.**អហិមំស** សាច់ពស់

៦.**សីហមំស** សាច់សីហៈ

៧.**ព្យគ្ឃមំស** សាច់ខ្លាធំ

៨.**ទីបមំស** សាច់ខ្លាដំបង

៩.**តរច្ឆមំស** សាច់ឆ្កែស្រុក

១០.**អច្ឆមំស** សាច់ខ្លាឃ្មុំ ។

**៥៧/សំនួរ កាយបរិហារ មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** កាយបរិហារមាន១៤យ៉ាងគឺៈ

១.មិនត្រូវទុកសក់វែង នឹងបានត្រឹមតែ២ខែ ឬ២ធ្នាប់ ។

២.មិនត្រូវទុក ពុកមាត់ ពុកចង្កា ។

៣.មិនត្រូវទុក ក្រចកវែង ត្រូវកាត់ចេញឲ្យស្មើនឹងសាច់ ។

៤.មិនត្រូវទុករោមច្រមុះវែង ត្រូវដកចេញដោយចន្ទាស ។

៥.មិនត្រូវឲ្យគេនាំចេញនូវរោមក្នុងទីបង្កៀត គឺក្នុងសំពត់និងក្លៀក វៀរលែងតែមានអាពាធ ។

៦.មិនត្រូវផាត់មុខ ដុសខាត់មុខ លាបមុខ ប្រស់មុខ ចឹមមុខ វៀរលែងតែអាពាធ ។

៧.មិនត្រូវតែងគ្រឿងប្រដាប់ផ្សេងៗ មានទំហូខ្សែខ្លួនជាដើមៗ

៨.មិនត្រូវឆ្លុះ មើលស្រមោលមុខ ក្នុងកញ្ចក់ ឬក្នុងវត្ថុដទៃ បើមិនអាពាធ ដំបៅមុខ ឆ្លុះដើម្បីលាបថ្នាំ ឬត្រួតមើលបាន ។

៩.មិនត្រូវអាក្រាតកាយ ក្នុងទីមិនសមគួរ ក្នុងវេលាមិនគួរ ។

១០.មិនត្រូវស្លៀកដណ្ដប់ដូចគ្រហស្ថ ។

១១.បន្ទោរបង់ឧច្ចារហើយ កាលបើមានទឹកនឹងមិនលៀងជំរះមិនបាន វៀរលែងទឹកគ្មាន ។

១២.មិនត្រូវធ្វើសត្ថកម្ម (ការកាត់ឬវះ) វត្ថិកម្ម (ការចងរឹត) ក្នុងចង្កៀត ឬជិតទីចង្កៀតត្រឹម២ធ្នាប់ បើធ្វើខ្លួនឯង ឬប្រើគេធ្វើត្រូវថុល្លច្ច័យ ។

១៣.ទំនៀមរបស់ភិក្ខុ ត្រូវប្រើឈើជម្រះធ្មេញ ។

១៤.ទឹកដែលប្រើប្រាស់ ត្រូវត្រងសិន ។

**៥៨/សំនួរ ភណ្ឌរបស់សង្ឃមានប៉ុន្មានប្រភេទ ?**

**ចម្លើយ** កណ្ឌរបស់សង្ឃមាន២ប្រភេទគឺ:

១.**លហុភណ្ឌ** របស់ស្រាល១

២.**គរុភណ្ឌ** របស់ធ្ងន់១។

គរុភណ្ឌក្នុងបាលីចាត់ថាមាន ៥ ផ្នែករួបរួមតាមឈ្មោះ របស់នោះៗ មាន ២៥ ដូច្នេះគឺ

១ទីដីនិងរបស់ដែលសង់ ឬដែលសាងក្នុងអារាមមានឈ្មោះ ២គឺ:

ក.**អារាមោ** របស់ដែលមានក្នុងអារាមគឺ សួនច្បារ១ ។

ខ.**អារាវត្ថុ** ទីដីដាំសួនច្បារ ។

២.ទីដីនិងរបស់ដែលសង់ ឬសាងជាវិហារ មាន២យ៉ាងដូចគ្នាគឺ:

១.**វិហារោ** កុដិដែលនៅ១ ។

២.**វិហារវត្ថុ** ទីដីសម្រាប់សង់លំនៅ១ ។

**៥៩/សំនួរ សមណកប្បគឺអ្វី ? មានប៉ុន្មានពួកគឺអ្វីខ្លះ ?**

**ចម្លើយ** សមណកប្ប គឺវត្ថុដែលគួរដល់សមណអាចឆាន់បានតាមសប្បាយ មាន៥យ៉ាងគឺ:

១.**អគ្គិបរិចិតំ** វត្ថុដែលបុគ្គលចំអិន ដោយកំដៅភ្លើង ។

២.**សត្ថបរិចិតំ** វត្ថុដែលបុគ្គលចិតបោះធ្លុះដោយកាំបិត ។

៣.**នខបរិចិតំ** វត្ថុដែលបុគ្គលកេះកោសចុចដោយក្រចក ។

៤.**អពីជំ** វត្ថុមិនដុះតទៅទៀត គឺផ្លែឈើខ្ចី ។

៥.**និព្វដពីជំ** វត្ថុដែលគេយកពូជ (គឺគ្រាប់) ចេញបានល្មុតជាដើម ។

**៦០/សំនួរ ព្រះសម្មាសម្ពុទ្ធទ្រង់ហាម ភិក្ខុសាមណេរមិនឲ្យបៀតបៀនពូជ៥យ៉ាងគឺ:**

១.**មូលវីជំ** ពូជកើតអំពីមើម ខ្ញី,រំដេង,ដំឡូង... ។

២.**ខន្ធវីជំ** ពូជកើតអំពីដើម ពោធិ៍,ជ្រៃ,លៀប... ។

៣.**ផឡុវីជំ** ពូជកើតអំពីថ្នាំង អំពៅ,ឬស្សី... ។

៤.**អគ្គពីជំ** ពូជកើតអំពីគល់ ឬចុង,ជីរលីងលាក់,បេក,ជីនាងវង... ។

៥.**វីជំវីជំ** ពូជកើតអំពីពូជ ស្រូវ,ពោត...។

**៦១/សំនួរ សាមណេរត្រូវប្រកបដោយអង្គប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** សាមណេរត្រូវប្រកបដោយអង្គ ៣ គឺ:

១.**កេសច្ឆេទនំ** កោរសក់ ។

២.**កាសាយអច្ឆាទនំ** ស្លៀកសំពត់កាសាយ ។

៣.**សរណទនំ** ឲ្យត្រៃសរណគមន៍ ។

**៦២/សំនួរ សាមណេរ បានឲ្យចីវរដល់សាមណេរឯទៀត**

**លុះក្រោធខឹងក៏ទៅដណ្ដើមចីវរយកមកដោយខ្លួនឯងក្ដីប្រើគេឲ្យទៅដណ្ដើមយកមកវិញក្ដី តើត្រូវទោសអ្វី? មាននៅក្នុងសិក្ខាបទណា? ឈ្មោះអ្វី?**

**ចម្លើយ** សាមណេរ បានឲ្យចីវរដល់សាមណេរឯទៀត លុះក្រោធខឹងក៏ទៅដណ្ដើមចីវរយកមកដោយខ្លួនឯងក្ដីប្រើគេឲ្យទៅដណ្ដើមយកមកវិញក្ដី ត្រូវទណ្ឌកម្មពេញទី មាននៅក្នុងលោកវជ្ជសិក្ខាបទ ត្រង់ចីវរចិន្ទនៈ។

**៦៣/សំនួរ ភិក្ខុបង្គាប់ឲ្យសាមណេរផឹកសុរា,សាមណេរក៏ផឹកដោយមានចិត្តប្រាថ្នាដែរ តើភិក្ខុនោះត្រូវទោសអ្វី ? សាមណេរត្រូវទោសអ្វី?**

**ចម្លើយ** ភិក្ខុនោះមិនត្រូវទោសអ្វីទេ ឯសាមណេរវិញត្រូវទោសនាសនង្គៈ។

**៦៤/សំនួរ អនាបត្តិកភិក្ខុ ក្នុងមេថុធម្មសិក្ខាបទមានប៉ុន្មាន ? អ្វីខ្លះ?**

**ចម្លើយ** អនាបត្តិកភិក្ខុ (ភិក្ខុដែលប្រព្រឹត្តហើយមិនត្រូវទោស) ក្នុងមេថុនធម្មសិក្ខាបទ៥ពួកគឺ:

១.ភិក្ខុមិនដឹងខ្លួន

២.ភិក្ខុឆ្កួត

៣.ភិក្ខុរើរវាយចិត្ត

៤.ភិក្ខុមានទុកវេទនាគ្របសង្កត់

៥.ភិក្ខុដើមបញ្ញត្តិ ។

**៦៥/សំនួរ សាមណេរដឹងថាលោកដែលទាយកបម្រុងនិង ប្រគេនដល់សង្ឃ ហើយបង្អោនសង្ឃលាភនោះ មកដើម្បីខ្លួនវិញ តើត្រូវទោសអ្វី ? មាននៅក្នុងណា ?**

**ចម្លើយ** សាមណេរដឹងថាលោកដែលទាយកបម្រុងនិង ប្រគេនដល់សង្ឃ ហើយបង្អោនសង្ឃលាភនោះ មកដើម្បីខ្លួនវិញ ត្រូវទណ្ឌកម្មពេញទី មាននៅក្នុងលោកវជ្ជសិក្ខា ត្រង់បរិណាត ។

**៦៦/សំនួរ អាបត្តិកភិក្ខុ ក្នុងមនុស្សវិគ្គហសិក្ខាបទមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** អាបត្តិកភិក្ខុ ក្នុងមនុស្សវិគ្គហសិក្ខាបទមាន ៣ យ៉ាង គឺ:

១.ត្រូវអាបត្តិទុក្កដ ដោយធ្វើរណ្តៅ ឬអ្វីមួយប៉ងនឹងសម្លាប់មនុស្ស ។

២.ត្រូវអាបត្តិថុល្លច្ច័យ បើមនុស្សប៉ះនឹងគ្រឿងសម្លាប់នោះ ហើយ កើតទុក្ខវេទនា ។

៣.ត្រូវអាបត្តិបារាជិក បើមនុស្សនោះស្លាប់ ។

**៦៧/សំនួរ ពូកប៉ុន្មានយ៉ាងដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុសាមណេរប្រើប្រាស់ ? អ្វីខ្លះ ? ចូររាប់ ?**

**ចម្លើយ** ពូកដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ សាម-ណេរប្រើប្រាស់មាន៥យ៉ាងគឺ:

១.**ឧណ្ណភិសិ** ពូកញាត់ដោយរោមកែស ។

២.**ចោឡភិសិ** ពូកញាត់ដោយសំពត់ ។

៣.**វាកភិសិ** ពូកញាត់ដោយសំបកឈើ ។

៤.**តិណភិសិ** ពូកញាត់ដោយស្មៅ ។

៥.**បណ្ណភិសិ** ពូកញាត់ដោយស្លឹកឈើ ។

**៦៨/សំនួរ សាមណេរប៉ុន្មានពួក ដែលសេពមេថុនធម្មហើយមិនត្រូវទោស ? អ្វីខ្លះ ?**

**ចម្លើយ** សាមណេរប៉ុន្មានពួក ដែលសេពមេថុនធម្មហើយមិនត្រូវទោសមាន៥ពួកគឺ:

១.**អជានន្តស្ស អសាទិយន្តស្ស** សាមណេរមិនដឹងខ្លួន ទាំងមិនត្រេកអរជាមួយ ។

២.**ឧម្មត្តកស្ស** សាមណេរឆ្កួត ។

៣.**ខិត្តចិត្តស្ស** សាមណេរមានចិត្តរវើរវាយ ។

៤.**វេទនដ្ដស្ស** សាមណេរដែលវេទនាគ្របសង្កត់ ។

**៥.អាទិកម្មិកស្ស** សាមណេរដើមបញ្ញត្តិ ។

**៦៩/សំនួរ អនាបត្តិកភិក្ខុ ក្នុងមនុស្សវិគ្គហសិក្ខាបទ មានប៉ុន្មានពួក ? អ្វីខ្លះ ?**

**ចម្លើយ** អនាបត្តិកភិក្ខុ ក្នុងមនុស្សវិគ្គហសិក្ខាបទមាន៧ពួកគឺ

១.ភិក្ខុមិនក្លែង

២.ភិក្ខុមិនដឹង

៣.ភិក្ខុមិនប្រាថ្នាឲ្យស្លាប់

៤.ភិក្ខុឆ្កួត

៥.ភិក្ខុដើមបញ្ញត្តិ

៦.ភិក្ខុរវើរវាយចិត្ត

៧.ភិក្ខុត្រូវវេទនាគ្របសង្កត់ ។

**៧០/សំនួរ សាមណេរជេរប្រទេច ឬពោលពាក្យចាត់ដោតសាមណេរផងគ្នា តើត្រូវទោសអ្វី ? នៅក្នុងសិក្ខាបទណា ?**

**ចម្លើយ** សាមណេរជេរប្រទេច ឬពោលពាក្យចាត់ដោតសាមណេរផងគ្នា ត្រូវទោសទណ្ឌកម្មពេញទី មាននៅក្នុងលោកវជ្ជសិក្ខាបទត្រង់ឱមសវាទៈ ។

**៧១/សំនួរ ពាក្យថា វិន័យនិងបញ្ញត្តិ ដូចគ្នា ឬផ្សេងគ្នា ? បើផ្សេងគ្នា ចូរពន្យល់ឲ្យល្មមស្តាប់ ?**

**ចម្លើយ** ពាក្យថា វិន័យនិងបញ្ញត្តិ ផ្សេងគ្នាគឺៈ

.វិន័យបានដល់បញ្ញត្តិ,អនុញ្ញាតនិងអភិសមាចាររួមទាំង៣ ពួកនេះហៅថា វិន័យ ។

.ចំណែកខាងបញ្ញត្តិវិញគឺជាខ១ ក្នុងចំណោមខទាំង៣ នៅក្នុងព្រះវិន័យនោះឯង ។

***៧២/សំនួរ សាមណេរនិយាយញុះញង់គេ និងសាមណេរនិយាយកុហក តើត្រូវទោស ដូចគ្នា ឬផ្សេងគ្នា ? ហើយបើផ្សេងគ្នា តើត្រូវទោសអ្វីខ្លះ ?***

**ចម្លើយ** សាមណេរនិយាយញុះញង់គេ ត្រូវទោសទណ្ឌកម្ម ឯសាមណេរនិយាយកុហកវិញ ត្រូវទោសនាសនង្គៈ ផ្សេងគ្នាដូចនេះ។

***៧៣/សំនួរ បញ្ញត្តិមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់និងពន្យល់ ?***

**ចម្លើយ** បញ្ញត្តិមាន៩យ៉ាងគឺៈ

១.**បឋមប្បញ្ញត្តិ ឬមូលប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ហាមជាដំបូងបំផុត ចំពោះអាទិកម្មិកបុគ្គល ។

២.**អនុប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ហាមប្រាមបន្ថែមបន្ទាប់ពីបឋមប្បញ្ញត្តិ ។

៣.**អនុប្បន្នប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ហាមប្រាម មុនទោសដែលកើតឡើង ឬបម្រាមដែលទ្រង់ហាមទុកឲ្យស្រេច បានដល់គរុទោស៨ប្រការ ។

៤.**សព្វត្ថប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ហាមទូទៅទាំងមជ្ឈមប្រទេស ទាំងបច្ចន្តប្រទេស ។

៥.**បទេសប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ហាមចំពោះតែភិក្ខុក្នុងមជ្ឈិមប្រទេសប៉ុណ្ណោះ ។សិក្ខាបទនេះមាន៤គឺៈ

ក.ការបំពេញឧបសម្បទាដោយគណៈសង្ឃមានវិន័យធរភិក្ខុ (គ្រូសូត្រ) ជាគម្រប់៥មិនបាន ។

ខ.មិនឲ្យភិក្ខុប្រើស្បែកជើង៤ជាន់ ។

គ.មិនឲ្យភិក្ខុស្រង់ទឹកជានិច្ច ។

ឃ.មិនឲ្យភិក្ខុប្រើប្រាស់កម្រាលស្បែក ។

៦.**សាធារណប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់បញ្ញត្តិទាំងភិក្ខុទាំងភិក្ខុនី ។

៧.**អសាធារណប្បញ្ញត្តិ** បានដល់សិក្ខាបទដែលទ្រង់ បញ្ញត្តិចំពោះតែភិក្ខុ ឬភិក្ខុនី ។

៨.**ឯកតោបញ្ញត្តិ** ដូចគ្នានឹងអសាធារណប្បញ្ញត្តិ ។

៩.**ឧភតោបញ្ញត្តិ** ដូចគ្នានិងសាធារណប្បញ្ញត្តិ ។

**៧៤/សំនួរ អាណត្តិ មានន័យសេចក្តីថាម៉េច ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់និងពន្យល់ ?**

**ចម្លើយ** អាណត្តិ បានសេចក្តីថាការបង្គាប់បញ្ជាប្រើឲ្យគេធ្វើ។ អាណត្តិនេះមាន២យ៉ាងគឺ:

១.**សាណត្តិក** បានដល់ការធ្វើខ្លួនឯង ឬប្រើគេឲ្យធ្វើក៏ត្រូវទោសដូចគ្នា ។ សិក្ខាបទដែលសង្គ្រោះចូលក្នុងសាណត្តិកនេះមាន ៣៨ សិក្ខាបទ មានអទិន្នាទានសិក្ខាបទជាដើម ។

២.**អនាណត្តិក** បានដល់សិក្ខាបទដែលធ្វើខ្លួនឯង ទើបត្រូវទោស បើប្រើគេឲ្យធ្វើមិនត្រូវទោសឡើយ សិក្ខាបទពួកនេះមាន ១៨២ ។

**៧៥/សំនួរ ព្រះពុទ្ធជាម្ចាស់ទ្រង់បញ្ញត្តិមិនឲ្យភិក្ខុបំបួសកុលបុត្រ ៣២ ជំពូកមានកំបុតដៃជើងជាដើម ។ ចុះបើភិក្ខុនៅតែបំបួសតើត្រូវទោសឬទេ ? ហើយតើកុលបុត្រនោះបានឡើងជាសាមណេរដែរ ឬមិនឡើង ?**

**ចម្លើយ** បើភិក្ខុនៅតែបំបួសកុលបុត្រ ៣២ ជំពូកនឹងត្រូវអាបត្តិទុក្កដ ប៉ុន្តែកុលបុត្តនោះនិងនៅតែឡើងជាសាមណេរពេញទី។

**៧៦/សំនួរ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ សាមណេរ**

**សឹងនិងអង្គុយបានលើគ្រែប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់ ?**

**ចម្លើយ** ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ សាមណេរ សឹងនិងអង្គុយបានលើគ្រែ៤យ៉ាងគឺ:

១.**មសារក** គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ។

២.**ពុន្ទិកាពទ្ធ** គ្រែដែលមានមេជាប់និងជើង ។

៣.**កុលិរបាទក** គ្រែដែលមានជើងដូចជាជើងក្តាម ។

៤.**អាហច្ចបាទក** គ្រែដែលមានជើងចុច ឬគ្រែដែលគេបញ្ចូលជើងក្នុងដំណាប់មេ ។

**៧៧/សំនួរ សាមណេរប្រាប់អាបត្តិអាក្រក់ គឺអាបត្តិសង្ឃាទិសេសរបស់ភិក្ខុដទៃ ដល់សាមណេរផងគ្នា តើត្រូវទោសអ្វីដែរ ?**

**ចម្លើយ** សាមណេរប្រាប់អាបត្តិអាក្រក់របស់ភិក្ខុដទៃដល់សាមណេរផងគ្នា ត្រូវទោសទណ្ឌកម្ម ។

**៧៨/សំនួរ អាបត្តិកភិក្ខុក្នុងឧត្តរិមនុស្សធម្មសិក្ខាបទមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** អាបត្តិកភិក្ខុឧត្តរិមនុស្សធម្មសិក្ខាបទមាន៣យ៉ាងគឺ:

១.ត្រូវអាបត្តិកភិក្ខុបារាជិកព្រោះពោលអួតឧត្តរិមនុស្សធម្មដែលមិនមានក្នុងខ្លួន ដោយសេចក្តីប្រាថ្នា ៣ មកគ្របសង្កត់ ។

២.ត្រូវអាបត្តិថុល្លច្ច័យ បើភិក្ខុនិយាយកុហកថា ភិក្ខុនៅក្នុង

វិហាររបស់ខ្លួន ជាព្រះអរហន្តប្រាប់ដល់អ្នកដទៃ ហើយគេមិនបានដឹងច្បាស់ទេ ។

៣.ត្រូវអាបត្តិទុក្កដ បើគេមិនបានដឹងច្បាស់ទេ ។

**៧៩/សំនួរ ឧត្តរិមនុស្សធម្មសិក្ខាបទ មានអង្គប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** ឧត្តរិមនុស្សធម្មសិក្ខាបទមានអង្គ៥គឺ:

១.ឧត្តរិមនុស្សធម្មមិនមានក្នុងខ្លួន ។

២.អួតឧត្តរិមនុស្សធម្ម ព្រោះប្រាថ្នាលាភ ។

៣.គ្មានអ្នកដទៃ ឬគ្មានគ្រឿងសម្គាល់ ។

៤.ពោលអួតប្រាប់ដល់មនុស្សជាតិ ។

៥.គេដឹងច្បាស់នូវសេចក្តីនោះ ។

**៨០/សំនួរ សុរានិងមេរ័យ ដូចគ្នា ឬផ្សេងគ្នា ? បើផ្សេងគ្នា តើផ្សេងយ៉ាងណា ? អ្វីហៅថាសុរា ? អ្វីហៅថាមេរ័យ ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** សុរានិងមេរ័យផ្សេងគ្នា គឺសុរាបានដល់វត្ថុ ដែលគេធ្វើដោយម្សៅជាដើម,ឯមេរ័យគេធ្វើដោយវត្ថុមានផ្កាឈើជាដើម ២ សុរាមាន ៥ យ៉ាងគឺ:

១.**បិដ្ឋសុរា** សុរាធ្វើដោយម្សៅ ។

២.**បូវសុរា** សុរាធ្វើដោយនំ ។

៣.**ឱទនសុរា** សុរាធ្វើដោយបាយ ។

៤.**កិណ្ណបក្ខិត្តា** សុរាដែលគេដាក់ពូជសុរា ។

៥.**សម្ភារសំយុត្តា** សុរាដែលគេប្រកបដោយគ្រឿងផ្សំផ្សេងៗ មានគ្រាប់ម្រេចនិងគ្រាប់ស្ពៃជាដើម ។

ឯមេរ័យ ជាគ្រឿងស្រវឹងមាន៥យ៉ាងដែរគឺ:

១.**បុប្ផាសវោ** ទឹកត្រាំធ្វើពីផ្កាឈើ ។

២.**ផលាសវោ** ទឹកត្រាំធ្វើពីផ្លែឈើ ។

៣.**មធ្វាសវោ** ទឹកត្រាំធ្វើពីផ្លែចន្ទន៍ ឬទឹកឃ្មុំ ។

៤.**គុឡាសវោ** ទឹកត្រាំដែលធ្វើពីទឹកអំពៅ ។

៥.**សម្ភារសំយុត្តោ** ទឹកត្រាំដែលគេប្រកបគ្រឿងផ្សំផ្សេងៗ មានផ្លែសម៉ និងផ្លែកន្ទួតព្រៃជាដើម ។

សុរា៥យ៉ាងនេះ និងមេរ័យ៥យ៉ាងនេះ បើភិក្ខុសាមណេរ ឆាន់ និងត្រូវទោសទាំងអស់ ។

**៨១/សំនួរ បាត្រប៉ុន្មានយ៉ាង ដែលព្រះពុទ្ធទ្រង់អនុញ្ញាតឲ្យ ភិក្ខុ សាមណេរប្រើប្រាស់ ? បាត្រប៉ុន្មានយ៉ាង ដែលព្រះអង្គទ្រង់ បញ្ញត្តិ ? អ្វីខ្លះ ?**

**ចម្លើយ** ប្រាត្រដីដុតនិងបាត្រដែក ដែលព្រះពុទ្ធទ្រង់អ នុញ្ញាតឲ្យភិក្ខុ សាមណេរប្រើប្រាស់ ។ បាត្រ១០យ៉ាងទៀតគឺ:

១.បាត្រមាស

២.បាត្រប្រាក់

៣.បាត្រកែវមណី

៤.បាត្រកែវផលិត

៥.បាត្រកែវពិទូរ្យ

៦.បាត្រកែវកញ្ចក់

៧.បាត្រសំរិទ្ធិ

៨.បាត្រសំណបាហាំង

៩.បាត្រសំណភក់

១០.បាត្រឈើ ។

ទាំង១០យ៉ាងនេះ ព្រះពុទ្ធទ្រង់ហាមមិនឲ្យភិក្ខុ សាមណេរប្រើប្រាស់ឡើយ ។

**៨២/សំនួរ ពាក្យថាបរិភោគមានន័យសេចក្តីយ៉ាងណា នៅក្នុងព្រះវិន័យ ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ចូររាប់និងអធិប្បាយ ?**

**ចម្លើយ** ពាក្យថា បរិភោគ មានន័យការប្រើប្រាស់ ការស៊ីចុក។ បរិភោគមាន ៤ យ៉ាងគឺ:

១.**ថេយ្យបរិភោគ** បរិភោគដោយការលួច បានដល់កាលបរិភោគ ប្រើប្រាស់នូវបច្ច័យរបស់ភិក្ខុសាមណេរទ្រុស្តសីល ។

២.**ឥណបរិភោគ** បរិភោគដោយជាប់បំណុល បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់ភិក្ខុ សាមណេរមានសីល តែពុំបានពិចារណាដោយបច្ច័យវេក្ខណៈ១ ។

៣.**ទាយជ្ជបរិភោគ** បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់សេក្ខបុគ្គល៧ពួកមានសោតាបន្នបុគ្គលជាដើម ។

៤.**សាមិកបរិភោគ** បរិភោគជនជាម្ចាស់ បានដល់ការបរិភោគប្រើប្រាស់នូវបច្ច័យរបស់អសេក្ខបុគ្គលគឺព្រះខីណាស្រព ។

**៨៣/សំនួរ សាមណេរដឹងថា កុដិជារបស់សង្ឃ មានភិក្ខុចូលទៅនៅមុនហើយ ក្លែងយកសំពត់ទៅដេកហើយបានអង្គុយ ឬជ្រៀតជ្រៀនក្នុងទីនោះ ដើម្បីនិងឲ្យភិក្ខុដែលនៅមុននោះ មានសេចក្ដីចង្អៀតចង្អល់ទញ់ទាល់ចិត្ត ហើយនឹងជៀសចេញទៅ តើត្រូវទោស អ្វី ? មាននៅក្នុងសិក្ខាបទណា ? ឈ្មោះអ្វី ?**

**ចម្លើយ** សាមណេរដឹងថា កុដិជារបស់សង្ឃ មានភិក្ខុចូលទៅនៅមុនហើយ ក្លែងយកសំពត់ទៅដេកហើយបានអង្គុយ ឬជ្រៀតជ្រៀនក្នុងទីនោះ ដើម្បីនិងឲ្យភិក្ខុដែលនៅមុននោះ មានសេចក្ដីចង្អៀតចង្អល់ទញ់ទាល់ចិត្ត ហើយនឹងជៀសចេញទៅ សាមណេរនោះត្រូវទណ្ឌកម្មពេញទី ។ មាននៅក្នុងលោកវជ្ជសិក្ខាបទ ត្រង់អនុប្បខជ្ជសិក្ខាបទ ។

**៨៤/សំនួរ អនាបត្តិកភិក្ខុក្នុងឧត្តរិមនុស្សធម្មសិក្ខាបទមាន ប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** អនាបត្តិកភិក្ខុក្នុងឧត្តរិមនុស្សធម្មសិក្ខាបទមាន ៦ពួក គឺ:

១.ភិក្ខុនិយាយស្មានថា ខ្លួនបានមគ្គផលមែន ។

២.ភិក្ខុនិយាយពីមគ្គផល ដោយឥតប្រាថ្នានិងពោលអួត ។

៣.ភិក្ខុឆ្កួត ។

៤.ភិក្ខុរវើរវាយចិត្ត ។

៥.ភិក្ខុត្រូវវេទនាគ្របសង្កត់ ។

៦.ភិក្ខុដើមបញ្ញត្តិ ។

**៨៥/សំនួរ អ្វីដែលហៅថា អតិរេកលាភ ? សំពត់ជាអតិរេកលាភមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** ដែលកើតឡើងដល់សង្ឃ ។ សំពត់ជាអតិរេកលាភ ដែលកើតឡើងដល់សង្ឃ ។ សំពត់ជាអតិរេកលាភមាន ៦ យ៉ាងគឺ:

១.**ខោមំ** សំពត់ធ្វើពីសំបកឈើ ។

២.**កប្បាសិកំ** សំពត់ធ្វើពីអម្បោះ ។

៣.**កោសេយ្យំ** សំពត់ធ្វើពីសូត្រ ។

៤.**កម្ពលំ** សំពត់ធ្វើពីរោមសត្វ ។

៥.**សាណំ** សំពត់ធ្វើពីការត្បាញលាយចម្រុះដោយសូត្រ និងអម្បោះ ។

សំពត់ទាំង៦យ៉ាងនេះ បើកើតឡើងជាអតិរេលាភ ព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ សាមណេរប្រើប្រាស់បាន ។

**៨៦/សំនួរ ចុះបិណ្ឌបាតប្បច្ច័យជាអតិរេកលាភវិញ មានប៉ុន្មានយ៉ាងដែរ ? អ្វីខ្លះ ?**

**ចម្លើយ** បិណ្ឌបាតប្បច្ច័យជាអតិរេកលាភមាន៧យ៉ាងគឺៈ

១.**សង្ឃភត្តំ** ភត្តប្រគេនចំពោះសង្ឃ ។

២.**ឧទ្ទេសភត្តំ** ភត្តដែលសង្ឃសម្តែងចំពោះភិក្ខុ ១រូប ឬ២រូប។

៣.**និមន្តនភត្តំ** ភត្តដែលទាយកនិមន្តឆាន់តាមសទ្ធា ។

៤.**សលាកភត្តំ** ភត្តដែលគេប្រគេនដោយចាប់ស្លាក ។

៥.**បក្ខិកភត្តំ** ភត្តដែលគេប្រគេនខាងខ្នើតឬខាងរនោច ។

៦.**ឧបោសថិកភត្តំ** ភត្តដែលគេប្រគេនក្នុងថ្ងៃឧបោសថ ។

៧.**បាដិបទិកភត្តំ** ភត្តដែលគេប្រគេនក្នុងថ្ងៃ១កើត ឬ១រោច ។

ភត្តទាំង៧យ៉ាងនេះ បើកើតជាអតិរេកលាភព្រះសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុ សាមណេរឆាន់បាន ។

**៨៧/សំនួរ សាមណេរឆាន់សម្លដែលគេលាយដោយស្រាធ្វើជាថ្នាំបន្សាប តើត្រូវទោសអ្វី ? ព្រោះហេតុអ្វី ?**

**ចម្លើយ** សាមណេរនោះមិនត្រូវទោសអ្វីទេ ព្រោះស្រានោះរលាយសាបជាតិស្រវឹងទៅហើយ ។

**៨៨/សំនួរ អង្គនៃអទិន្នាទានសិក្ខាបទ ក្នុងបារាជិកមានប៉ុន្មាន? អ្វីខ្លះ ?**

**ចម្លើយ** អង្គនៃអទិន្នាទានសិក្ខាបទ ក្នុងបារាជិកមាន៥យ៉ាងគឺ

១.ទ្រព្យមានម្ចាស់ជាមនុស្ស(មិនមែនជាប្រេត ឬសត្វតិរច្ឆាន) ថែរក្សា ។

២.ដឹងថាទ្រព្យនោះមានម្ចាស់ថែរក្សា ។

៣.ជាទ្រព្យមានតម្លៃ១បាតឡើងទៅ ។

៤.មានចិត្តគំនិតនឹងលួច ។

៥.លួចបានមក ។

**៨៩/សំនួរ ចុះសមុដ្ឋានក្នុងអទិន្នាទានសិក្ខាបទមានប៉ុន្មានយ៉ាងដែរ ? អ្វីខ្លះ ? ចូររាប់ហើយពន្យល់ ?**

**ចម្លើយ** សមុដ្ឋានក្នុងអទិន្នាទានសិក្ខាបទមាន៣គឺ:

១.**កាយចិត្ត** មានកាយប្រកបដោយចិត្ត ។

២.**វាចាចិត្ត** មានវាចាប្រកបដោយចិត្ត ។

៣.**កាយវាចាចិត្ត** មានកាយប្រកបដោយវាចានិងចិត្ត ។

**៩០/សំនួរ សេនាសនៈជាអតិរេកលាភ មានប៉ុន្មានយ៉ាង ?**

**អ្វីខ្លះ?**

**ចម្លើយ** សេនាសនៈជាអតិរេកលាភមាន៥យ៉ាងគឺៈ

១.**វិហារោ** កុដិធំ ឬសាលា ។

២.**អឌ្ឍយោគោ** បង្ហា ។

៣.**បាសាទោ** ប្រាសាទ ឬកុដិថែវ មានជាន់ច្រើន ។

៤.**ហម្មិយំ** ប្រាសាទមានកំពូល ឬឥតកំពូល ឬថែវទាប ។

៥.**គូហា** រូងភ្នំ ។

**៩១/សំនួរ ចុះភេសជ្ជប្បច្ច័យជាអតិរេកលាភមានប៉ុន្មានដែរ? អ្វីខ្លះ?**

**ចម្លើយ** ភេសជ្ជប្បច្ច័យជាអតិរេកលាភក៏មាន៥យ៉ាងដែរគឺៈ

១.**សប្បិ** ទឹកដោះរាវ ។

២.**នវនីតំ** ទឹកដោះខាប់ ។

៣.**តេលំ** ប្រេង ។

៤.**មធុ** ទឹកឃ្មុំ ។

៥.**ផាណិតំ** ស្ករអំពៅ ។

**៩២/សំនួរ សាមណេរឃើញលលកមួយគូ គិតនឹងសម្លាប់ ប៉ុន្តែស្រាប់តែលលកនោះហើរទៅប៉ះនិងជញ្ជាំងវិហារស្លាប់ទៅ តើសាមណេរនោះត្រូវទោសអ្វីដែរ? ព្រោះហេតុអ្វី?**

**ចម្លើយ** សាមណេរនោះមិនត្រូវទោសអ្វីទេ ព្រោះខ្វះអង្គ១ គឺ តែនមរណំ សត្វស្លាប់ដោយព្យាយាមបានសេចក្តីថា សត្វនោះស្លាប់ មិនមែនដោយសាមណេរនោះសម្លាប់ឡើយ គឺវាស្លាប់ដោយខ្លួនឯង ព្រោះហើរទៅប៉ះនឹងជញ្ជាំងវិហារ ។

**៩៣/សំនួរ អង្គនៃមនុស្សវិគ្គហៈសិក្ខាបទមានប៉ុន្មាន ? អ្វីខ្លះ? ចូររាប់ ?**

**ចម្លើយ** អង្គនៃមនុស្សវិគ្គហៈសិក្ខាបទមាន៥គឺៈ

១.ជាមនុស្សជាតិ ។

២.ដឹងថាមានជីវិត ។

៣.គិតនឹងសម្លាប់ ។

៤.ព្យាយាមនឹងសម្លាប់ ។

៥.មនុស្សស្លាប់ដោយព្យាយាមនោះ ។

**៩៤/សំនួរ មនុស្សវិគ្គហៈសិក្ខាបទ មានសមុដ្ឋានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** មនុស្សវិគ្គហៈសិក្ខាបទ មានសមុដ្ឋាន៣គឺៈ

១.**កាយចិត្ត** ត្រូវទោសព្រោះមានកាយប្រកបដោយចិត្តប៉ង ។

២.**វាចាចិត្ត** ត្រូវទោសព្រោះមានវាចាប្រកបដោយចិត្តប៉ងឲ្យ គេស្លាប់ ។

៣.**កាយវាចាចិត្ត** មានទោសព្រោះប្រកបព្រមដោយអង្គ៣ ។

**៩៥/សំនួរ** តើថ្នាំផ្សំពីស្លឹកឈើមានប៉ុន្មាន ? អ្វីខ្លះ ?

**ចម្លើយ** ថ្នាំផ្សំពីស្លឹកឈើមាន៥យ៉ាងគឺ:

ក.**និម្ពបណ្ណំ** ស្លឹកស្តៅ ។

ខ.**កុដជបណ្ណំ** ស្លឹកស្វែងគង់ ។

គ.**បដោលបណ្ណំ** ស្លឹកអម្បែងថ្ងៃ ។

ឃ.**សុលសិបណ្ណំ** ស្លឹកម្រះព្រៅ ឬជីរលីងលាក់ ។

ង.**កប្បាសិកបណ្ណំ** ស្លឹកកប្បាសជាដើម ។

**៩៦/សំនួរ ពាក្យថា កាលិក មានន័យសេចក្តីយ៉ាងណាក្នុងព្រះវិន័យ ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ក្នុងកាលិកនីមួយៗ បានដល់អ្វីខ្លះ ?**

**ចម្លើយ** ពាក្យថា កាលិក មានន័យសេចក្តីថា វត្ថុដែលបរិភោគបានក្នុងកាល ឬវត្ថុដែលប្រកបដោយកាល ។ កាលិកនេះមាន ៤យ៉ាងគឺ:

១.**យាវកាលិក** របស់ដែលភិក្ខុ សាមណេរទទួលយក ហើយអាចទុកឆាន់បានតាំងពីអរុណរះដរាបដល់ថ្ងៃត្រង់ បានដល់ខាទនីយនិងភោជនីយាហារផ្សេងៗ មានបង្អែមចំអាបត្រីសាច់ អង្ករជាដើម ។

២.**យាមកាលិក** របស់ដែលភិក្ខុ សាមណេរទទួលមកហើយ អាចទុកឆាន់បានមួយថ្ងៃ១យប់បានដល់ទឹក ៨យ៉ាង (អដ្ឋបាន)គឺៈ

ក.**អម្ពបានំ** ទឹកធ្វើពីផ្លែស្វាយ ។

ខ.**ជម្ពុបានំ** ទឹកធ្វើពីផ្លែព្រីង ។

គ.**ចោចបានំ** ទឹកធ្វើពីផ្លែចេកមានគ្រាប់ ។

ឃ.**មធុបានំ** ទឹកធ្វើពីផ្លែស្រគំ ។

ង.**មោចបានំ** ទឹកធ្វើពីផ្លែចេកឥតគ្រាប់ ។

ច.**មុទ្ទិកបានំ** ទឹកធ្វើពីផ្លែចន្ទន៍ ។

ឆ.**សលុកបានំ** ទឹកធ្វើពីផ្លែក្រឱឈូក ។

ជ.**ផារុសកបានំ** ទឹកធ្វើពីផ្លែមាក់ប្រាំង ។

ពុំនោះសោតទេ បានដល់ទឹកដែលធ្វើពីផ្លែឈើ ៨ យ៉ាងទៀត

ក.**កោសម្ពបានំ** ទឹកផ្លែស័ង្ឃរ ។

ខ.**កោលបានំ** ទឹកផ្លែពុទ្រាតូច ។

គ.**ពទ្របានំ** ទឹកផ្លែពុទ្រាធំ ។

ឃ.**ឃតបានំ** ទឹកដោះរាវ-ថ្លា ។

ង.**តេលបានំ** ទឹកធ្វើពីគ្រាប់ល្ងជាដើម ។

ច.**បយោបានំ** ទឹកដោះស្រស់ ។

ឆ.**យាគុបានំ** ទឹកបបរ ។

ជ.**រសបានំ** ទឹកធ្វើពីរសរុក្ខជាតិផ្សេងៗ មានរសស្ទឹក និងផ្កាជាដើម ។

**៩៧/សំនួរ សត្តាហកាលិក របស់ដែលភិក្ខុសាមណេរទទួលមកហើយ អាចទុកឆាន់បានប៉ុន្មានថ្ងៃ ? បានដល់ភេសជ្ជៈអ្វីខ្លះ ?**

**ចម្លើយ** សត្តាហកាលិក របស់ដែលភិក្ខុសាមណេរទទួលមកហើយ អាចទុកឆាន់បាន៧ថ្ងៃ បានដល់ភេសជ្ជៈ៥យ៉ាងគឺ:

ក.**សប្បិ** ទឹកដោះរាវ ។

ខ.**នវនីតំ** ទឹកដោះខាប់ ។

គ.**តេលំ** ប្រេង ។

ឃ.**មធុ** ទឹកឃ្មុំ ។

ង.**ផាណិតំ** ស្ករអំពៅ ។

**៩៨/សំនួរ តើយាវជីវិត របស់ដែលភិក្ខុសាមណេរទទួលបានមកហើយអាចទុកឆាន់ទាល់តែអស់បានដល់ថ្នាំកែរោគផ្សេងៗ ឬថ្នាំផ្សំពីមើមឈើមានអ្វីខ្លះ ?**

**ចម្លើយ** យាវជីវិត របស់ដែលភិក្ខុសាមណេរទទួលបានមកហើយអាចទុកឆាន់ទាល់តែអស់បានដល់ថ្នាំកែរោគផ្សេងៗ ឬថ្នាំផ្សំពីមើមឈើគឺ:

ក.**ហលិទ្ទំ** មើមរមៀត ។

ខ.**សិង្គវេរំ** មើមខ្ញី ។

គ.**វចំ** មើមសំពាន់ ។

ឃ.**វចត្តំ** មើមប្រស់ ។

ង.**អតិវិសំ** មើមអាចម៍ក្តឹស ។

ច.**កដុករោហិណី** មើមរំដេង ។

ឆ.**ឧរីសំ** មើមស្បូវភ្លាំង ។

ជ.**ភទ្ទមុត្តក** មើមស្មៅក្រវាញជ្រូក ។

**៩៩/សំនួរ** តើថ្នាំដែលគេផ្សំពីផ្លៃឈើមានអ្វីខ្លះ ?

**ចម្លើយ** ថ្នាំដែលគេផ្សំពីផ្លៃឈើមានដូចជាៈ

ក.**វិលង្គំ** ផ្លៃពិលិង្គ ។

ខ.**បិប្ផលិ** ផ្លៃដីប្លី ។

គ.**មរិចំ** ផ្លៃម្រេច ។

ឃ.**ហរីតកំ** ផ្លៃសម៉ ។

ង.**វិភីតកំ** ផ្លៃសម៉ពិភេក ។

ច.**អាលមកំ** ផ្លៃកន្ទួតព្រៃ ។

ឆ.**គោថផលំ** ផ្លៃក្រវាញជាដើម ។

ដទៃពីនេះ មានកាលិលាយចម្រុះគ្នា គឺកាលិកខ្លះលាយនិង កាលិកដទៃ មានកំណត់ឲ្យប្រើបានត្រឹម កាលនៃរបស់កាលិកដែល

មានកាលខ្វី តួយ៉ាងដូចជាថ្នាំបុកផង់ ជាយាវជីវិក យកទៅច្របល់លាយនិងទឹកឃ្មុំជាសត្តាហកាលិក ថ្នាំនោះក៏មានកាលត្រឹម៧ថ្ងៃទៅតាមគ្នា ។ គ្រឿងទេសខ្លះដូចជាក្រវាញកាន់ក្លូជាយាវជីវិក គេតាក់តែងផ្សំនិងបាយដែលដាំដោយខ្ទិះដូង ក៏ក្លាយទៅជាយាវកាលិកតាមគ្នា ។

**១០០/សំនួរ សត្តាហកាលិក និងយាវជីវិក ដែលភិក្ខុសាមណេរទទួលប្រគេនមួយយប់ហើយ លោកហាមមិនឲ្យយកទៅលាយនិងយាវជីវិកទេ តួយ៉ាងដូចជាយកស្ករដែលទទួលប្រគេនទុកមួយយប់ហើយ ឆាន់ជាមួយនំ ។ បម្រាមនេះលោកមានឈ្មោះអ្វី ? ក្នុងសង្ឃាយនាទីប៉ុន្មាន ? ក្នុងគម្ពីរឈ្មោះអ្វីដែរ ?**

**ចម្លើយ** សត្តាហកាលិក និងយាវជីវិក ដែលភិក្ខុ សាមណេរទទួលប្រគេនមួយយប់ហើយ លោកហាមមិនឲ្យយកទៅ លាយនិងយាវជីវិកទេ តួយ៉ាងដូចជាយកស្ករដែលទទួលប្រគេនទុក មួយយប់ហើយឆាន់ជាមួយនំ ។ បម្រាមនេះលោកមានឈ្មោះថា សត្តសត្តិក្ខន្ធកៈ ក្នុងគ្រាធ្វើទុតិយសង្គាយនា ។ ក្នុងគម្ពីរចុល្លវគ្គប្រាប់ ថាត្រូវទោស ព្រោះឆាន់របស់ជាសន្និធិលាយជាមួយទឹកអដ្ឋបាន ។

**១០១/សំនួរ** ផ្លែឈើព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យធ្វើទឹកអដ្ឋបាន ចុះមានផ្លែអ្វីទ្រង់ហាមប្រាមដែរ ? បើមានតើបានដល់អ្វីខ្លះ?

ចូររាប់ ?

**ចម្លើយ** ឈើព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យធ្វើទឹក អដ្ឋបាន មានផ្លែស្រូវទ្រង់ហាមមិនឲ្យធ្វើទឹកអដ្ឋបាន គឺស្រូវ៧យ៉ាងគឺ:

ក.**សាលី** ស្រូវសាលី ។

ខ.**វិហី** ស្រូវខ្សាយ ។

គ.**យវោ** ស្រូវដំណើប ។

ឃ.**គោធុមោ** ស្រាង ។

ង.**កន** ថៅ ។

ច.**វរកោ** ពោលស្អួយ ឬកន្ទុយដំរី ។

ឆ.**កុទ្រូសកោ** ស្មៅគែលលក ។

**១០២/សំនួរ តើទ្រង់ហាមចំពោះមហាផល (ផ្លែឈើធំ) មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** ទ្រង់ហាមចំពោះមហាផល (ផ្លែឈើធំ) មាន៩យ៉ាង គឺ:

ក.**នាឡិកេរផលំ** ផ្លែដូង ។

ខ.**តាលផលំ** ផ្លែត្នោត ។

គ.**បនសំផលំ** ផ្លែខ្នុរ ។

ឃ.**លពុជផលំ** ផ្លែខ្នុរសម្ល ។

ង.**តិបុសផលំ** ផ្លែឪឡឹក ។

ច.**បុស្សផលំ** ផ្លែត្រសក់ ។

ឆ.**ឯឡាលុកផលំ** ផ្លែត្រឡាច ។

ជ.**កុម្ភណ្ឌផលំ** ផ្លែល្ពៅ ។

ឈ.**អឡាពុផលំ** ផ្លែឃ្លោក ។

**១០៣/សំនួរ អាបត្តិសង្ឃាទិសេសគឺអ្វី ? ចូរពន្យល់ឲ្យល្អម ស្តាប់ ?**

**ចម្លើយ** អាបត្តិសង្ឃាទិសេសគឺជាទោសជាតដែលភិក្ខុត្រូវធ្វើ ខ្លួនឲ្យមានសង្ឃជាខាងដើម កណ្តាលនិងខាងចុង ។ បើភិក្ខុត្រូវ ទោសនេះហើយត្រូវចូលរួមបរិវាសកម្មចំពោះសង្ឃជាខាងដើមត្រូវ សូមមានត្តចំពោះសង្ឃឲ្យសង្ឃដាក់មូលាបត្តិជាកណ្តាល រួចត្រូវសូម អព្ភាសនៈ មិនត្រូវបានទទួលអភិវាទកម្មជាដើម អពីបតក្កភិក្ខុ ឡើយ។ នេះចំពោះក្នុងពេលលើកវត្ត បើដាក់វត្តចេញហើយអាច ទទួលបាន ។

**១០៤/សំនួរ សុក្កវិសដ្ឋិសិក្ខាបទ គឺអ្វី ? អាបត្តិនេះជាសីលវិ បត្តិ ឬអានាចារវិបត្តិ ?**

**ចម្លើយ** សុក្កវិសដ្ឋិសិក្ខាបទ គឺជាឈ្មោះអាបត្តិសង្ឃាទិសេស សិក្ខាបទទី១ ។ អាបត្តិនេះជាសីលវិបត្តិ ។

**១០៥/សំនួរ សុក្កវិសដ្ឋិសិក្ខាបទនេះមានអង្គប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** សុក្កវិសដ្ឋិសិក្ខាបទនេះមានអង្គ ៣ គឺ:

ក.មានចិត្តប្រាថ្នានឹងឲ្យទឹកអសុចិចេញ ។

ខ.ព្យាយាមធ្វើឲ្យទឹកអសុចិចេញ ។

គ.ទឹកអសុចិបានឃ្លាតចេញមកដោយព្យាយាមនោះ ។

**១០៦/សំនួរ វត្តរបស់ភិក្ខុ សាមណេរគឺអ្វី ? មានប៉ុន្មាន ? អ្វីខ្លះ?**

**ចម្លើយ** វត្តរបស់ភិក្ខុ សាមណេរគឺប្រពៃណី ទំនៀបទម្លាប់ ដែលភិក្ខុ សាមណេរត្រូវធ្វើ ប្រព្រឹត្តចំពោះទីកន្លែង ឬបុគ្គលមាន៣ យ៉ាងគឺ:

១.**កិច្ចវត្ត** វត្តគឺកិច្ចដែលត្រូវធ្វើ ។

២.**ចរិយាវត្ត** វត្តមារយាទដែលគួរប្រព្រឹត្តកាន់ ។

៣.**វិធីវត្ត** វត្តគឺប្រពៃណី របៀបដែលចេះដឹង ។

**១០៧/សំនួរ សាមណេរដឹងថាភិក្ខុ ឯទៀតត្រូវទុដ្ឋុល្លាបត្តិគឺ អាបត្តិសង្ឃាទិសេស ហើយក៏ជួយបិទបាំងអាបត្តិនោះ តើត្រូវទោស អ្វី ?**

**ចម្លើយ** សាមណេរដឹងថាភិក្ខុ ឯទៀតត្រូវទុដ្ឋុល្លាបត្តិគឺ អាបត្តិសង្ឃាទិសេស ហើយក៏ជួយបិទបាំងអាបត្តិនោះ ត្រូវទោស

ទណ្ឌកម្មពេញទី ។

**១០៨/សំនួរ អាបត្តិនិស្សគ្គិយបាចិត្តិយ មានន័យសេចក្តីយ៉ាងណា ? មានប៉ុន្មាន ? អ្វីខ្លះ ? ចូរអធិប្បាយពន្យល់ ?**

**ចម្លើយ** អាបត្តិនិស្សគ្គិយ មានន័យសេចក្តីថា បើភិក្ខុត្រូវទោសនោះៗហើយ ត្រូវលះនូវវត្ថុដែលប្រព្រឹត្តខុសជាមុន ទើបសម្តែងអាបត្តិដាច់ ឧទាហរណ៍ ដូចក្នុងបឋមកឋិនសិក្ខាបទថា:

កាលបើអស់អំណាចអានិសង្សកឋិនហើយ ភិក្ខុអាចទុកអតិរេកចីវរបាន១ថ្ងៃយ៉ាងយូរ បើឲ្យហួសពីនេះទៅ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយដូច្នេះ ដើម្បីនឹងសម្តែងអាបត្តិនេះឲ្យដាច់ត្រូវលះអតិរេកចីវរនោះជាមុនសឹមសម្តែងអាបត្តិទើបដាច់ ។ បើនៅតែទុកចីវរនោះដដែរមិនអាចសម្តែងអាបត្តិដាច់ឡើយ ។ និស្សគ្គិយបាចិត្តិយនេះមាន៣០ បែកចេញទៅតាមវគ្គមាន៣គឺ:

១.**ចីវរវគ្គ** មានសិក្ខាបទ ១០ ។

២.**កោសិយវគ្គ** មានសិក្ខាបទ១០ ។

៣.**បត្តវគ្គ** មានសិក្ខាបទ ១០ ។

**១០៩/សំនួរ អាបត្តិបារាជិក និងអាបត្តិសង្ឃាទិសេសមានកងអាបត្តិអាណាខ្លះដែលទទួលរង ? ព្រោះហេតុអ្វី ? ចូរពន្យល់ ?**

**ចម្លើយ** អាបត្តិបារាជិក និងអាបត្តិសង្ឃាទិសេសមានកង

អាបត្តិ២ សម្រាប់ទទួលរងគឺ អាបត្តិថុល្លច្ច័យ និងអាបត្តិទុក្កដ ព្រោះថា បើកាលណាភិក្ខុប្រព្រឹត្តខុស ទើបត្រូវអាបត្តិសង្ឃាទិសេស បើមិនគ្រប់អង្គទេ ក៏ត្រូវអាបត្តិរាយរងតៗមក ឧទាហរណ៍ ក្នុងអទិន្នាទានសិក្ខាបទ បើលួចរបស់មានតម្លៃតាំងពី៥ មាសកឡើងទៅ ត្រូវអាបត្តិបារាជិក បើលួចរបស់តិចជាង៥មាសក ត្រូវអាបត្តិថុល្លច្ច័យ,បើលួចរបស់ខ្វះពី១មាសក ត្រូវអាបត្តិទុក្កដ ។

**១១០/សំនួរ អាបត្តិនិងអនាបត្តិកភិក្ខុក្នុងសុក្កវិសដ្ឋិសិក្ខាបទមានប៉ុន្មានយ៉ាង ? អ្វីខ្វះ ?**

**ចម្លើយ** អាបត្តិកភិក្ខុក្នុងសុក្កវិសដ្ឋិសិក្ខាបទមាន ៣ពួកគឺ:

១.ត្រូវសង្ឃាទិសេស បើគេព្យាយាមរហូតទឹកអសុចិឃ្លាតចេញ ។

២.ត្រូវអាបត្តិថុល្លច្ច័យ បើគិតព្យាយាមតែទឹកអសុចិមិនឃ្លាតចេញ ។

៣.ត្រូវអាបត្តិទុក្កដ បើគ្រាន់តែព្យាយាម ។ ចំណែកអនាបត្តិកភិក្ខុសុក្កវិសដ្ឋិសិក្ខាបទមាន៦គឺ:

១.ភិក្ខុយល់សប្តិ

២.ភិក្ខុគ្មានបំណងព្យាយាម

៣.ភិក្ខុឆ្កួត

៤.ភិក្ខុមានចិត្តរវើរវាយ

៥.ភិក្ខុត្រូវវេទនាគ្របសង្កត់

៦.ភិក្ខុដើមបញ្ញត្តិ ។

**១១១/សំនួរ ភិក្ខុ-សាមណេរដាច់សីលដោយហេតុប៉ុន្មានយ៉ាង ? អ្វីខ្លះ ? តើត្រូវទោសទាំងអស់ ឬយ៉ាងណា ? ព្រោះអ្វី ?**

**ចម្លើយ** ភិក្ខុ-សាមណេរដាច់សីលដោយហេតុ២យ៉ាងគឺ:

១.ដាច់ដោយការប្រព្រឹត្តកន្លងសិក្ខាបទ ។

២.ដាច់ដោយធ្វើមរណកាល ។

ការដាច់សីលទាំង២នេះ, ការដាច់ដោយការប្រព្រឹត្តកន្លងសិក្ខាបទ ទើបមានទោស ឯការដាច់ដោយធ្វើមរណកាល គ្មានត្រូវទោសអ្វីទេ ។

**១១២/សំនួរ កិច្ចវត្តគឺអ្វី ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** កិច្ចវត្តគឺការប្រព្រឹត្តប្រតិបត្តិជានិច្ច ដែលភិក្ខុសាមណេរត្រូវធ្វើ ។ កិច្ចវត្តនេះមាន១០យ៉ាងគឺ:

១.ភិក្ខុ-សាមណេរជាសទ្ធិវិហារិក គួរយលចិត្តទុកដាក់បម្រើឧបជ្ឈាយ៍របស់ខ្លួន អស់កាលដែលអាស្រ័យនៅនឹងលោក ។

២.ភិក្ខុជាឧបជ្ឈាយ៍ គួរមានចិត្តអើពើតបសទ្ធិវិហារិកវិញអស់កាលដែលសទ្ធិវិហារិកនៅជាមួយ ។

៣.ភិក្ខុ-សាមណេរជាអាគន្តុក ត្រូវប្រព្រឹត្តឲ្យសមគួរនៃខ្លួនជាភ្ញៀវ ។

៤.ភិក្ខុ-សាមណេរជាម្ចាស់ទីកន្លែង កាលបើមានអាគន្តុក ត្រូវធ្វើបដិសណ្ឋារដោយសមគួរ ។

៥.ភិក្ខុ-សាមណេរ មុននឹងចេញទៅទីដទៃ ត្រូវរៀបចំទុកដាក់គ្រឿងសម្ភារៈឲ្យបានស្អាត ។

៦.មុននឹងចូលបិណ្ឌបាតក្នុងលង្វែកភូមិ ភិក្ខុសាមណេរត្រូវប្រព្រឹត្តខ្លួនឲ្យត្រឹមត្រូវតាមទំនៀម ។

៧.ពេលឆាន់អាហារ ភិក្ខុ-សាមណេរគួរឲ្យប្រព្រឹត្តឲ្យត្រឹមត្រូវ

៨.ភិក្ខុ-សាមណេរមានម្ចប់ឈើជាសេនាសនៈ តែបើក្នុងរដូវវស្សាត្រូវរកទីសេនាសនៈដែលជាគ្មានទទឹកភ្លៀង ដែលមនុស្សធ្វើឡើង ឬធ្វើដោយខ្លួនឯង ។

៩.ភិក្ខុ-សាមណេរត្រូវរក្សាវច្ចកុដិ (បង្គន់) ឲ្យស្អាត ។

១០.ភិក្ខុ-សាមណេរគួរជួយព្យាបាលភិក្ខុ សាមណេរដទៃដែលមានអាពាធតាមកាលគួរ ។

**១១៣/សំនួរ អនាចារគឺអ្វី ? សាមណេរប្រព្រឹត្តអនាចារ សង្ឃក៏បានហៅខ្លួនមកសាកសួរ ក៏ក្លែងនិយាយត្រឡប់ត្រឡិនក្តី ស្ងៀមមិននិយាយក្តី បើសង្ឃបានសូត្រប្រកាសសេចក្តីនោះចប់ នៅតែធ្វើ**

**ដូច្នេះទៀត តើត្រូវទោសអ្វី? មាននៅសិក្ខាបទណា?**

**ចម្លើយ** អនាចារ គឺការប្រព្រឹត្តអំពើមិនគួរគប្បីជាហេតុនាំឲ្យទាស់ក្អែកអ្នកដទៃទាំងពួង ។

បើសាមណេរប្រព្រឹត្តអនាចារ សង្ឃបានហៅខ្លួនមកសាកសួរក៏ក្លែងនិយាយត្រឡប់ត្រឡិន ឬនៅស្ងៀម ហើយបើសង្ឃសូត្រប្រកាសសេចក្តីនោះចប់ ក៏នៅតែធ្វើដូច្នេះទៀត និងត្រូវទោសទណ្ឌកម្មមាននៅក្នុងអញ្ញវាទកសិក្ខាបទ ។

**១១៤/សំនួរ អាបត្តិនិស្សគ្គិយបាចិត្តិយដូចគ្នា ឬផ្សេងគ្នា ? បើផ្សេងគ្នា តើផ្សេងយ៉ាងណា ? សុទ្ធិកបាចិត្តិយមានប៉ុន្មានយ៉ាងដែរ ? អ្វីខ្លះ?**

**ចម្លើយ** អាបត្តិទាំងពីនេះផ្សេងគ្នាគឺ មានទោសប៉ុនគ្នា,ផ្សេងគ្នាគឺ និស្សគ្គិយបាចិត្តិយ កាលបើត្រូវហើយ ត្រូវលះ ឬទម្លាយនូវវត្ថុនោះចេញសិនទើបសម្តែងដាច់ ចំណែកខាងសុទ្ធិកបាចិត្តិយវិញ ជាកងអាបត្តិមានឈ្មោះ២ទៅទៀតគឺ:

ក.**បកតិបាចិត្តិយ** បើភិក្ខុត្រូវសម្តែងអាបត្តិចេញ តែម្តងនឹងបានរួចទោសគ្មានវិន័យកម្មជាបុព្វកិច្ចឡើយ ។

ខ.**ភេទកាទិបាចិត្តិយ** បើភិក្ខុត្រូវទោសហើយ ត្រូវទំលាយកណ្ឌានោះចោលចេញ ទើបសម្តែងអាបត្តិរួច ។

**១១៥/សំនួរ កាយសំសគ្គសិក្ខាបទ ជាវិបត្តិអ្វី ? មានអង្គ ប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** កាយសំសគ្គសិក្ខាបទ ជាសីលវិបត្តិ មានអង្គ៥គឺៈ

១.ស្ត្រីជាមនុស្ស ។

២.ភិក្ខុដឹងថាជាស្ត្រី ។

៣.ចាប់ពាល់ដោយចិត្តត្រេកអរ ។

៤.ព្យាយាមតាមតម្រេក នៃការចាប់ពាល់នោះ ។

៥.បានចាប់ពាល់នូវកាយស្ត្រីនោះ ។

**១១៦/សំនួរ ក្នុងបណ្ដានាសនង្គៈទាំង១០ កាលបើត្រូវទោសហើយ ព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវផ្សឹកសាមណេរនោះចេញ ។ តើមានសិក្ខាបទណាដែលអនុញ្ញាតឲ្យបួសវិញបានអត់ ? តើមានសិក្ខាបទណាដែលព្រះហាមមិនឲ្យបួសវិញជាដាច់ខាតឬទេ ? ព្រោះអ្វី ?**

**ចម្លើយ** បើសាមណេរប្រព្រឹត្តខុសក្នុងសិក្ខាបទនៃនាសនង្គៈពីបាណាតិបាតដល់មជ្ជបាយ ត្រូវផុតសាមណេរភេទ តែបើចង់បួសវិញក៏បាន ។ ប៉ុន្តែបើសាមណេរប្រព្រឹត្តកន្លងហើយៗប្រាប់ដល់ឧបជ្ឈាយ៍ៗ ក៏គ្រាន់តែឲ្យសរណគមន៍ និងសីលទុកជាការស្រេច ។ ចំពោះអង្គទី៦,៧,៨ (ពុទ្ធស្ស ធម្មស្ស និងសង្ឃស្ស អវណ្ណំ ភាសិតិ) បើសាមណេរប្រព្រឹត្តខុសហើយ ឧបជ្ឈាយ៍ចារ្យត្រូវសម្ដែងទោសប្រាប់

ដល់សាមណេរនោះថាកុំប្រព្រឹត្តដូច្នេះទៀត បើសាមណេរនៅតែប្រព្រឹត្ត ត្រូវធ្វើទណ្ឌកម្មឲ្យសម្ដែងទោសកណ្ដាលជំនុំសង្ឃរួចឲ្យសីល និងសរណគមន៍ក៏ជាការស្រេចដែរ ។

ចំណែកខាងសិក្ខាបទទី៩ ក៏ត្រូវធ្វើដូចក្នុងសិក្ខាបទទី៦,៧ និង៨ដែរ តែបើមិនស្ដាប់ត្រូវផ្សឹកចេញ តែអាចឲ្យបួសវិញបាន ។

ចំណែកអង្គទី១០ ត្រូវឧបជ្ឈាយ៍ចារ្យចេញ ហើយមិនត្រូវបំបួសវិញឡើយ ។

**១១៧/សំនួរ វត្តដូចម្ដេច ដែលហៅថាចរិយាវត្ត ? មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** ចរិយាវត្ត គឺការធ្វើសណ្ដាប់ធ្នាប់ឲ្យល្អសមរម្យ និងសាមណេរភេទ ។ ចរិយាវត្តនេះមាន១០យ៉ាងដោយសង្ខេបគឺ:

១.មិនឲ្យជាន់ផ្ទត់សំពត់ ដែលគេលាតក្នុងទីនិមន្ត ។

២.កុំឲ្យអង្គុយលើអាសនៈដោយពុំទាន់បានពិចារណាជាមុន

៣.មិនត្រូវអង្គុយលើអាសនៈជាមួយស្ត្រី ឬមនុស្សខ្ទើយ តើបើអង្គុយជាមួយមានអាសនៈមិនស្មើគ្នាបាន ។

៤.មិនត្រូវក្រោកចោលភិក្ខុ-សាមណេរកំពុងឆាន់ ។

៥.ត្រូវបិទទ្វារឲ្យជិតមុននិងសម្រាកក្នុងវេលាថ្ងៃ ។

៦.មិនត្រូវបន្ទោរបង់ឧច្ចារៈ បស្សាវៈ ចោលសម្រាម ឬរបស់

ជាសំណល់ទៅក្រៅជញ្ជាំង ឬក្រៅកំពែង ។

៧.មិនត្រូវឡើងដើមឈើ វៀរលែងតែមានកិច្ចធុរៈ ដូចជាវង្វេងផ្លូវជាដើម ។

៨.មិនត្រូវទៅមើលគេរាំស្តាប់ចម្រៀង ឬប្រគំភ្លេងផ្សេងៗ ។

៩.មិនត្រូវសូត្រធម៌ ដោយសម្លេងច្រៀងដ៏វែងៗ ។

១០.មិនត្រូវចាប់វត្ថុជាអនាមាស៦យ៉ាងគឺ:

ក.ស្ត្រីព្រមទាំងគ្រឿងតែងខ្លួនរបស់ស្ត្រី និងរូបដែលធ្វើមានទ្រង់ទ្រាយជាស្ត្រី ។

ខ.មាសប្រាក់និងរតនៈ ។

គ.សាស្ត្រាវុធផ្សេងៗ ជាគ្រឿងប្រទូស្តដល់រាងកាយ ជាគ្រឿងធ្វើការងារ ដូចជាពូថៅជាដើម មិនរាប់បញ្ចូលក្នុងសាស្ត្រាវុធនេះទេ។

ឃ.គ្រឿងចាប់សត្វលើគោក ឬក្នុងទឹក ។

ង.គ្រឿងប្រគំគ្រប់បែបយ៉ាង ។

ច.គ្រាប់ស្រូវនិងផ្លែឈើដែលជាប់នៅនិងដើម ។

**១១៨/សំនួរ សាមណេរសម្លាប់សត្វឲ្យបាត់បង់ជីវិតត្រូវឧបជ្ឈាយ៍ចាប់ផ្សឹកចេញ តែអាចបួសវិញបាន ។ ចុះមានការសម្លាប់អ្វីផ្សេងពីនេះហើយបួសវិញមិនបានដែរ ? បើមានតើសម្លាប់អ្វីខ្លះ ?**

**ចូររាប់មកមើល ?**

**ចម្លើយ** មាន សាមណេរសម្រាប់ជន៣ពួកគឺ: មាតា១ បិតា១ ព្រះអរហន្ត១ កាលបើផ្សឹកហើយ មិនអាចឲ្យបួសជាសាមណេរវិញឡើយ ។

**១១៩/សំនួរ អាបត្តិកភិក្ខុ ក្នុងកាយសំសគ្គសិក្ខាបទមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** អាបត្តិកភិក្ខុ ក្នុងកាយសំសគ្គសិក្ខាបទមាន៣យ៉ាងគឺ

១.ត្រូវអាបត្តិសង្ឃាទិសេស បើអង្អែលស្រីដោយកាយរបស់ខ្លួន ។

២.ត្រូវអាបត្តិថុល្លច្ច័យ បើចាប់ពាល់ស្ទាបរបស់ដែលជាប់និងកាយ ។

៣.ត្រូវអាបត្តិទុក្កដ បើយកវត្ថុដែលជាប់នៅនឹងខ្លួន ទៅស្ទាបអង្អែលវត្ថុដែលជាប់និងកាយស្ត្រី ។

**១២០/សំនួរ ចុះអានាបត្តិកភិក្ខុក្នុងសិក្ខាបទនេះមានប៉ុន្មានយ៉ាងដែរ ? អ្វីខ្លះ ?**

**ចម្លើយ** អានាបត្តិកភិក្ខុក្នុងសិក្ខាបទនេះមាន៨គឺ:

១.ភិក្ខុមិនក្លែង ។

២.ភិក្ខុភ្លេចភ្លាំងស្មារតី ។

៣.ភិក្ខុមិនដឹង ។

៤.ភិក្ខុមិនមានចិត្តត្រេក ។

៥.ភិក្ខុឆ្កួត ។

៦.ភិក្ខុរវើរវាយចិត្ត ។

៧.ភិក្ខុមានវេទនាគ្របសង្កត់ ។

៨.ភិក្ខុដើមបញ្ញត្តិ ។

**១២១/សំនួរ ភិក្ខុឲ្យគេធ្វើសន្ថតលាយដោយសូត្រ តើត្រូវទោសអ្វី ? ដើម្បីឲ្យរួចទោស តើត្រូវធ្វើដោយវិធីណា ?**

**ចម្លើយ** ភិក្ខុឲ្យគេធ្វើសន្ថតលាយដោយសូត្រ ត្រូវអាបត្តិនិស្សគ្គិយបាចិត្តិយ គឺសន្ថតជាវត្ថុនិស្សគ្គិយ ភិក្ខុនោះត្រូវអាបត្តិបាចិត្តិយ ។ បើចង់ឲ្យរួចទោសសម្តែងអាបត្តិដាច់ ត្រូវលះបង់វត្ថុនោះជាមុនសិន ។

**១២២/សំនួរ អង្គនៃទុដ្ឋុល្លវាចាសិក្ខាបទមានប៉ុន្មានអ្វីខ្លះ ?**

**ចម្លើយ** អង្គនៃទុដ្ឋុល្លវាចាសិក្ខាបទ (ភិក្ខុនិយាយ ពាក្យអាក្រក់ដោយមានតម្រេកចំពោះនិមិត្តស្រី) មាន៥យ៉ាងគឺ:

១.មនុស្សជាស្ត្រី ។

២.ដឹងថាជាស្ត្រី ។

៣.ត្រេកអរនឹងការនិយាយសម្តីអាក្រក់ ។

៤.និយាយចែចង់ចំពោះមគ្គ ស្រីណាមួយតាមតម្រេក ។

៥.ស្ត្រីនោះបានដឹងច្បាស់ភ្លាមៗ ។

**១២៣/សំនួរ ពេលណាជាពេលចាំវស្សា ? ការចាំវស្សាមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ? ក្នុងផ្នែកនិមួយៗត្រូវចូលពីពេលណាដល់ពេលណា ?**

**ចម្លើយ** វស្សារដូវជាពេលចាំវស្សា ។ ព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យភិក្ខុសាមណេរចូលកាន់វស្សា ចាប់ពីថ្ងៃ១រោច ខែអាសាឍ រហូតទល់ថ្ងៃ១៥កើត ខែអស្សុជ មានរយៈពេល៣ខែ ។ បើឆ្នាំជាអធិកមាសគឺមានការលើកខែអាសាឍពីរដង ជាបឋមសាឍនិងទុតិយាសាឍ ត្រូវឲ្យចូលវស្សាពីថ្ងៃ១រោច ខែទុតិយាសាឍទៅ ។ ការចាំវស្សាមាន២យ៉ាងគឺ ១ បុរិមិកាវស្សា ភិក្ខុ សាមណេរត្រូវចូលវស្សាពីថ្ងៃ ១ រោចខែអាសាឍ (បឋមាសាឍ ឬទុតិយាសាឍ) ទៅទល់និងថ្ងៃ១៥កើត ខែអស្សុជ ។ ២ បច្ឆិមកាវស្សា ភិក្ខុ សាមណេរត្រូវចូលវស្សានៅថ្ងៃ១ រោជ ខែស្រាពណ៍ រហូតទៅទល់និងថ្ងៃ១៥កើត ខែកត្តិក ។

**១២៤/សំនួរ សាមណេរលួចទ្រព្យគេ ត្រូវឧបជ្ឈាយ៍ ឬអាចារ្យផ្សឹកចេញ តែបើអនុញ្ញាតឲ្យបួសវិញក៏បាន ចុះមានការលួចបែបណាដែលមិនអាចឲ្យបួសវិញបាន ?**

**ចម្លើយ** មាន គឺថេយ្យសំវាស សាមណេរលួចរួមសំវាស គឺខ្លួន

មិនមែនជាភិក្ខុបានឧបសម្បាទា តែក្លែងខ្លួនជាភិក្ខុទៅធ្វើសង្ឃកម្មជាមួយភិក្ខុដទៃ ។ សាមណេរប្រព្រឹត្តខុសបែបនេះ កាលបើឧបជ្ឈាយ៍ឬអាចារ្យផ្សឹកចេញហើយមិនត្រូវបំបួស ឬឲ្យបួសវិញឡើយ ។

**១២៥/សំនួរ អាបត្តិក និងអនាបត្តិកភិក្ខុក្នុងទុដ្ឋុល្លវាចា មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** អាបត្តិកភិក្ខុក្នុងសិក្ខាបទនេះមាន៣គឺ:

១.ត្រូវអាបត្តិសង្ឃាទិសេស បើនិយាយសរសើរ ឬតិះដៀលនូវទ្វារមគ្គស្រីណាមួយ ។

២.ត្រូវអាបត្តិថុល្លច្ច័យ បើភិក្ខុនិយាយ ឬតិះដៀលនូវសរីរៈស្ត្រីក្រៅពីទ្វារមគ្គចេញ ។

៣.ត្រូវអាបត្តិទុក្កដ បើភិក្ខុនិយាយសរសើរ ឬតិះដៀលវត្ថុដែលជាប់និងកាយស្ត្រី ។

អនាបត្តិកភិក្ខុក្នុងសិក្ខាបទនេះមាន៥យ៉ាងគឺ:

១.ភិក្ខុកំពុងធ្វើអត្ថាធិប្បាយរឿងអ្វី១ ។

២.ភិក្ខុដែលកំពុងប្រៀនប្រដៅធម៌ ។

៣.ភិក្ខុឆ្កួត ។

៤.ភិក្ខុដែលកំពុងប្រៀនប្រដៅ ។

៥.ភិក្ខុដើមបញ្ញត្តិ ។

**១២៦/សំនួរ បួសមានប៉ុន្មានយ៉ាងក្នុងព្រះពុទ្ធសាសនា ?**

**ចម្លើយ** បួសមាន២យ៉ាងនៅក្នុងព្រះពុទ្ធសាសនាគឺ:

១.**ពាហិបព្វជ្ជា** បួសខាងក្រៅព្រះពុទ្ធសាសនា ។

២.**ធម្មវិនយបព្វជ្ជា** បួសក្នុងធម៌វិន័យរបស់ព្រះពុទ្ធ ។

**១២៧/សំនួរ ធម្មវិន័យបព្វជ្ជាបើចែកតាមគោលដើមមានប៉ុន្មានយ៉ាង ?**

**ចម្លើយ** ធម្មវិន័យបព្វជ្ជាបើចែកតាមគោលដើមមាន២យ៉ាងគឺ

១.បួសជាសាមណេរ ហៅថា បព្វជ្ជា ។

២.បួសជាភិក្ខុ ហៅថា ឧបសម្បទា ។

**១២៨/សំនួរ បួសបើចែកតាមប្រភេទមានប៉ុន្មានយ៉ាង ?**

**ចម្លើយ** បួសបើចែកតាមប្រភេទមាន៦យ៉ាងគឺ:

១.**ឧបកីឡិកា** បួសលេងល្បែង ។

២.**ឧបជីវិកា** បួសគ្រាន់តែចិញ្ចឹមជីវិត ។

៣.**ឧបមុយ្សិកា** បួសខ្ជិលរៀនសូត្រ ។

៤.**ឧបទូស្សិកា** បួសគ្រាន់តែប្រទូស្តសាសនា ។

៥.**ឧបចិណ្ណិកា** បួសដើម្បីសន្សំទ្រព្យ ។

៦.**ឧបនិស្សរណា** បួសដើម្បីចេញចាកកាម ។

**១២៩/សំនួរ ទោសប៉ុន្មានយ៉ាងដែលភិក្ខុចូលទៅកាន់ត្រកូល**

**ហួសវេលា ?អ្វីខ្លះ ?**

**ចម្លើយ** ទោស៥យ៉ាងដែលភិក្ខុចូលទៅកាន់ត្រកូល ហួសវេលាគឺៈ

១.**មាតុគាមស្ស អភិណ្ហទស្សនំ** បានឃើញមាតុគ្រាមញយៗ។

២.**ទស្សនេ សតិ សំសគ្គោ** កាលបើឃើញហើយនាំឲ្យមានចិត្តជាប់ជំពាក់ចំពោះមាតុគ្រាមនេះ ។

៣.**សំសគ្គេ សតិវិស្សាសោ** កាលបើមានចិត្តជាប់ជំពាក់ហើយសេចក្ដីស្និទ្ធស្នាលក៏កើតមានឡើង ។

៤.**វិស្សាសោ សតិ ឱតារោ** កាលបើមានសេចក្ដីស្និទ្ធស្នាលហើយការពុះពោរឡើងនៃរាគក៏មាន ។

៥.**ឱតិណ្ណចិត្តស្សេតំ ភិក្ខុនោ បាដិកង្ខំ** ទោសនេះរមែងប្រាកដដល់ភិក្ខុដែលមានចិត្តត្រូវរាគត្រូវគ្របសង្កត់ ។

**១៣០/សំនួរ ត្រកូលប្រកបដោយអង្គប៉ុន្មាន ដែលបព្វជិតមិនត្រូវទៅ ? អ្វីខ្លះ ?**

**ចម្លើយ** ត្រកូលប្រកបដោយអង្គ៩ដែលបព្វជិតមិនត្រូវទៅនោះគឺៈ

១.**ន មនាបេន បច្ចុដ្ឋេន្តិ** មិនក្រោកទទួលដោយសេចក្ដីគោរព

២.**ន មនាបេន អភិវាទេន្តិ** មិនថ្វាយបង្គំដោយគោរព ។

៣.**ន មនាបេន អាសនំ ទេន្តិ** មិនឲ្យអាសនៈដោយពេញចិត្ត។

៤.**សទ្ធមស្ស បរិគ្គយ្ហន្តិ** លាក់លៀមរបស់ធាន់ ។

៥.**បណីតម្បិ លូខំ ទេន្តិ** ឲ្យរបស់ថោកទាបមិនឲ្យរបស់ថ្លៃថ្នូរ

៦.**ពហុសម្បិ ថោកំ ទេន្តិ** មានច្រើនឲ្យតិច ។

៧.**អសក្កច្ចំ ទេន្តិ អសកច្ចំ** ឲ្យដោយមិនគោរពមិនឲ្យដោយគោរព ។

៨.**ន ឧបនីសីទន្តិ ធម្មស្សវនាយ** មិនអង្គុយដើម្បីស្តាប់ធម៌ ។

៩.**ភាសិតស្ស ន រមិស្សន្តិ** មិនត្រេកអរចំពោះភាសិតនៃបព្ជិត ។

**១៣១/សំនួរ តើរបស់ដាច់ប្រគេនមានប៉ុន្មានយ៉ាង ? គឺអ្វីខ្លះ?**

**ចម្លើយ** របស់ដាច់ប្រគេនមាន៧យ៉ាងគឺ:

១.ភិក្ខុក្រោកចាកអាសនៈ

២.ភិក្ខុអនិច្ចធម្ម

៣.ភិក្ខុលាចាកសិក្ខាបទ

៤.ភិក្ខុចូលសាសនានិគ្រន្ថ

៥.ភិក្ខុ អនុសម្បន្នកាន់យក

៦.ភិក្ខុ សត្វតិរច្ឆានពាំយក

៧.ភិក្ខុ មនុស្សមានភេទពីរ ។

**១៣២/សំនួរ សីមាដែលបាត់បង់មានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** សីមាដែលបាត់បង់មាន២យ៉ាងគឺ:

ក.សង្ឃសូត្រដកនៅសីមានោះ

ខ.អស់សាសនាព្រះពុទ្ធ ។

**១៣៣/សន្ទួរ អាហារមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** អាហារមាន៤យ៉ាងគឺ:

ក.កលឡីកាហារ គឺ បាយ

ខ.ចេតនាកាហារ គឺចិត្តត្រេកអរ

គ.ផស្សាកាហារ គឺការប៉ះពាល់

ឃ.វិញ្ញាណាកាហារ គឺការដឹង ។

**១៣៤/សំនួរ ឈ្មោះរបស់ចីវរមានប៉ុន្មានខណ្ឌ ? គឺអ្វីខ្លះ ?**

**ចម្លើយ** ឈ្មោះរបស់ចីវរមាន៤ខណ្ឌគឺ:

១.បញ្ចខណ្ឌ (ខណ្ឌប្រាំ)

២.សត្តខណ្ឌ (ខណ្ឌប្រាំពី)

៣.នវខណ្ឌ (ខណ្ឌប្រាំបួន)

៤.ឯកទសខណ្ឌ (ខណ្ឌដប់មួយ) ។

**១៣៥/សំនួរ រោគមានសមុដ្ឋានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** រោគមានសមុដ្ឋាន៤យ៉ាងគឺ:

ក.រោគកើតអំពីកម្ម

ខ.រោគកើតអំពីឧតុ (រដូវ)

គ.រោគកើតអំពីអាហារ

ឃ.រោគកើតអំពីចិត្ត ។

**១៣៦/សំនួរ ឧបោសថមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** ឧបោសថមាន៤យ៉ាងគឺ:

ក.សង្ឃឧបោសថ មានភិក្ខុ៤អង្គឡើងទៅ

ខ.គណឧបោសថ មានភិក្ខុ៣អង្គ

គ.បារិសុទ្ធិឧបោសថ មានភិក្ខុ២អង្គ

ឃ.អធិដ្ឋានឧបោសថ មានភិក្ខុ១អង្គ ។

**១៣៧/សំនួរ បុព្វករណមានប៉ុន្មានយ៉ាង ? អ្វីខ្លះ ?**

**ចម្លើយ** បុព្វករណមាន៤យ៉ាងគឺ:

១.សម្មជ្ជនី (បោសសំអាត)

២.បទីប (ប្រទីប អុជបំភ្លឺ)

៣.ឧទក (ដម្កល់ទឹកសម្រាប់ឆាន់)

៤.អាសនៈ (ក្រាលកន្ទេល,ព្រំ) ។

**១៣៨/សំនួរ តើបុព្វកិច្ចមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** បុព្វកិច្ចមាន៥គឺ:

១.នាំឆន្ទៈ (ប្រាប់ពីភិក្ខុមានអាពាធ)

២.បារិសុទ្ធិ (ប្រាប់សេចក្តីបរិសុទ្ធ)

៣.ឧតុក្ខាន (ប្រាប់អំពីរដូវ)

៤.គណនា (រាប់ចំនួនភិក្ខុ)

៥.ឱវាទ (ឲ្យវាទដល់ភិក្ខុនី, ឥឡូវអត់មានភិក្ខុនីទេ) ។

**១៣៩/សំនួរ ធម៌ដែលគួរបូជាមានប៉ុន្មាន ? អ្វីខ្លះ ?**

**ចម្លើយ** ធម៌ដែលគួរបូជាមាន៣គឺ:

១.សេក្ខធម៌

២.អសេក្ខធម៌

៣.លោកុត្តរធម៌ ។

**១៤០/សំនួរ តើសេក្ខធម៌មានអ្វីខ្លះ ?**

**ចម្លើយ** សេក្ខធម៌មាន៧គឺ:

ក.សោតាបត្តិមគ្គ

ខ.សោតាបត្តិផល

គ.សកទាគាមិមគ្គ

ឃ.សកទាគាមិផល

ង.អនាគាមិមគ្គ

ច.អនាគាមិផល

៨.អរហត្តមគ្គ ។

**អសេក្ខធម៌** នោះមានតែ អរហត្តផល១ទេ ។

**១៤១/សំនួរ បើភិក្ខុនៅចាំវស្សាហើយ បើអាចចេញទៅដោយសត្តាហករណីកិច្ចមានប៉ុន្មានយ៉ាង? អ្វីខ្លះ?**

**ចម្លើយ** បើភិក្ខុនៅចាំវស្សាហើយ បើអាចចេញទៅដោយសត្តាហករណីកិច្ចមាន៤យ៉ាងគឺ:

១.សហធម្មិក ឬមាតាបិតាឈឺ បើដឹងហើយ និមន្តទៅបាន។

២.សហធម្មិក អផ្សុកចង់សឹក បើដឹងហើយអាចចេញទៅដើម្បីរម្ងាប់បាន ។

៣.មានកិច្ចសង្ឃកើតឡើង ដូចជាវិហារទ្រុឌទ្រោម,គ្រោះទឹកជំនន់ ក្នុងវេលានោះជាដើម អាចចេញទៅដើម្បីស្វែងរកសម្ភារៈយកមកជួសជុលបាន ។

៤.ទាយកគេនិមន្ត បំពេញកុសល ប្រើមនុស្សឲ្យទៅនិមន្តចេញទៅដើម្បីបំពេញបុណ្យកុសលបាន ។

បាលីចូលវស្សា

**ឱកាស ឥមស្មឹ អាវាសេ ឥមំ តេ មាសំ វស្សំ ឧបេមិ ។**

**ទុតិយម្បិ ឥមស្មឹ អាវាសេ ឥមំ តេ មាសំ វស្សំ ឧបេមិ ។**

**តតិយម្បិ ឥមស្មឹ អាវាសេ ឥមំ តេ មាសំ វស្សំ ឧបេមិ ។**

បាលីចេញវស្សា

សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ ។ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ ។

ទុតិយម្បិ សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ ។ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ។

តតិយម្បិ សង្ឃំ ភន្តេ បវារេមិ ទិដ្ឋេន វា សុតេន វា បរិសង្កាយ វា វទន្តុ មំ អាយស្មន្តោ ។ អនុកម្បំ ឧបាទាយ បស្សន្តោ បដិករិស្សាមិ។

បាលីលើកសត្តាហៈ

សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេយេវ បុន និវត្តិស្សាមិ។

ទុតិយម្បិ សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេយេវ បុន និវត្តិស្សាមិ ។

តតិយម្បិ សចេ មេ អន្តរាយោ នត្ថិ សត្តាហព្ភន្តរេយេវ បុន និវត្តិស្សាមិ ។

ពិធីអនុមោទនាកឋិន

(ភិក្ខុចាស់) អត្ថតំ អាវុសោ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទថ ។

(ភិក្ខុខ្ចី) អត្ថតំ ភន្តេ សង្ឃស្ស កឋិនំ ធម្មិកោ កឋិនត្ថារោ អនុមោទាមិ ។

ពីធីក្រាលកឋិន

**ឥមាយ សង្ឃាដិយា កឋិនំ អត្ថរាមិ ។**

ខ្ញុំក្រាលកឋិន ដោយសង្ឃាដីនេះ ។

**ឥមានិ ឧត្តរាសង្គេន កឋិនំ អត្ថរាមិ ។**

ខ្ញុំក្រាលកឋិន ដោយចីពរនេះ ។

**ឥមិនា អន្តរវាសកេន កឋិនំ អត្ថរាមិ ។**

ខ្ញុំករុណាក្រាលកឋិន ដោយស្បង់នេះ ។

ធម៌ពិន្ទុសង្ឃាដី,ចីវរ និងស្បង់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ ពិន្ទុ កប្បំ ករោមិ ។

ទុតិយម្បិ ឥមំ ពិន្ទុ កប្បំ ករោមិ ។

តតិយម្បិ ឥមំ ពិន្ទុ កប្បំ ករោមិ ។

ធម៌អធិដ្ឋានសង្ឃាដី

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ សង្ឃាដឹ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានចីវរ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ ឧត្តរាសង្គំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានស្បង់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ អន្តរវាសកំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានបាត្រ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ អយ បត្តំ អធិដ្ឋាមិ ។

ទុតិយម្បិ ឥមំ អយ បត្តំ អធិដ្ឋាមិ ។

តតិយម្បិ ឥមំ អយ បត្តំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានហង្សរាក់

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ អង្កសិកំ អធិដ្ឋាមិ ។

ទុតិយម្បិ ឥមំ អង្កសិកំ អធិដ្ឋាមិ ។

តតិយម្បិ ឥមំ អង្កសិកំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានវទ្ធពន្ធ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ អង្កាយពន្ធនំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ អង្កាយពន្ធនំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ អង្កាយពន្ធនំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានឧត្តរាសង្គ

ឥមំ  អង្កពន្ធនំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ  អង្កពន្ធនំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ  អង្កពន្ធនំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានកម្រាល

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមំ បច្ចត្ថរណំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ បច្ចត្ថរណំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ បច្ចត្ថរណំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានកន្សែងជូតមុខ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ មុខបុញ្ឆនចោឡំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ មុខបុញ្ឆនចោឡំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ មុខបុញ្ឆនចោឡំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានសំពត់ងូតទឹកភ្លៀង

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមំ វស្សិកសាដកំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ វស្សិកសាដកំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ វស្សិកសាដកំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានសំពត់ងូតទឹក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
ឥមំ ឧទកសាដិកំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ ឧទកសាដិកំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ ឧទកសាដិកំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានសំពត់សម្រាប់ទ្រាប់អង្គុយ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ និសីទនំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ និសីទនំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ និសីទនំ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានសំពត់រុំដំបៅ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ កណ្ឌុប្បដិច្ឆាទឹ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ កណ្ឌុប្បដិច្ឆាទឹ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ កណ្ឌុប្បដិច្ឆាទឹ អធិដ្ឋាមិ ។

ធម៌អធិដ្ឋានសម្ពត់សម្រាប់ត្រងទឹក

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ បរិសាវនំ អធិដ្ឋាមិ ។
ទុតិយម្បិ ឥមំ បរិសាវនំ អធិដ្ឋាមិ ។
តតិយម្បិ ឥមំ បរិសាវនំ អធិដ្ឋាមិ ។

ធម៌ដកអធិដ្ឋាន សង្ឃាដី,ចីវរ,ស្បង់..........។

យើងគ្រាន់តែថា បច្ចុទ្ធរាមិ ជំនួសនូវពាក្យថា អធិដ្ឋាមិ តែប៉ុណ្ណោះ ។ (ក្រៅពីនោះនៅដូចដើមទាំងអស់) ។

មើលឧទាហរណ៍ខាងក្រោម ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ ។
ទុតិយម្បិ ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ ។
តតិយម្បិ ឥមំ សង្ឃាដឹ បច្ចុទ្ធរាមិ ។

ធម៌សម្តែងអាបត្តិ (ភិក្ខុខ្ចីសម្តែងមុន ភិក្ខុចាស់អ្នកសួរ)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។
នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(ភិក្ខុខ្ចី) ឱកាស សព្វាតា អាបត្តិយោ អារោចេមិ ។

សព្វាតា អាបត្តិយោ អាពោចេមិ ។

សព្វាតា អាបត្តិយោ អាពោចេមិ ។

សព្វា លហុកា អាបត្តិយោ អាពោចេមិ ។

សព្វា លហុកា អាបត្តិយោ អាពោចេមិ ។

សព្វា លហុកា អាបត្តិយោ អាពោចេមិ ។

អហំ ភន្តេ សម្ពហុនានា វត្ថុកាយោ និស្សគ្គិយយាយោ បាចិត្តិយយាយោ ទុព្ភាសិតាយាយោ ទុក្កដាយាយោ ថុល្លច្ចយាយោ អាបន្នោតា តុម្ហមូលេ បដិទេសេមិ ។

(ភិក្ខុចាស់) បស្សសិ អាវុសោតា អាបត្តិយោ ។

(ភិក្ខុខ្ចី) ឧកាស អាម ភន្តេ បស្សាមិ ។

(ភិក្ខុចាស់) អាយតឹ អាវុសោ សំវរេយ្យាសិ ។

(ភិក្ខុខ្ចី) សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

ទុតិយម្បិ សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

តតិយម្បិ សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្ត យិស្សាមិ។

(ភិក្ខុខ្ចី) ឧកាស អហំ ឯកំ ទុក្កដំ អាបន្នោតំ តុម្ហមូលេ បដិទេសេមិ ។

(ភិក្ខុចាស់) បស្សសិ អាវុសោតា អាបត្តិយោ ។

(ភិក្ខុខ្ចី) ឱកាស អាម ភន្តេ បស្សាមិ ។

(ភិក្ខុចាស់) អាយតឹ អាវុសោ សំវរេយ្យាសិ ។

(ភិក្ខុខ្ចី) សាធុ សុដ្ឋុ ភន្តេ សំវរេយ្យាមិ ។

ទុតិយម្បិ សាធុ សុដ្ឋុ ភន្តេ សំវរេយ្យាមិ ។

តតិយម្បិ សាធុ សុដ្ឋុ ភន្តេ សំវរេយ្យាមិ ។

នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ។

ធម៌សម្ដែងអាបត្តិ (ភិក្ខុចាស់សម្ដែងមុន ភិក្ខុខ្ចីអ្នកសួរ)

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

(ភិក្ខុចាស់) សព្វាតា អាបត្តិយោ អារោចេមិ ។

សព្វាតា អាបត្តិយោ អារោចេមិ ។

សព្វាតា អាបត្តិយោ អារោចេមិ ។

អហំ អាវុសោ សម្ពហុនានា វត្ថុកាយោ និស្សគ្គិយយាយោ បាចិត្តិយយាយោ ទុព្ភាសិតាយាយោ ទុក្កដាយាយោ ថុល្លច្ចយាយោ អាបន្នោតា តុម្ហមូលេ បដិទេសេមិ ។

(ភិក្ខុខ្ចី) ឱកាស បស្សថ ភន្តេតា អាបត្តិយោ ។

(ភិក្ខុចាស់) អាម អាវុសោ បស្សាមិ ។

(ភិក្ខុខ្ចី) អាយតឹ ភន្តេ សំវរេយ្យាថ ។

(ភិក្ខុចាស់) សាធុ សត្ថុ អាវុសោ សំវរេយ្យាមិ ។

ទុតិយម្បិ សាធុ សត្ថុ អាវុសោ សំវរេយ្យាមិ ។

តតិយម្បិ សាធុ សត្ថុ អាវុសោ សំវរេយ្យាមិ ។

នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ។

(ភិក្ខុខ្ចី) ឱកាស អហំ ឯកំ ទុក្កដំ អាបន្នោតំ តុម្ហមូលេ បដិទេសេមិ ។

(ភិក្ខុចាស់) បស្សសិ អាវុសោតា អាបត្តិយោ ។

(ភិក្ខុខ្ចី) ឱកាស អាម ភន្តេ បស្សាមិ ។

(ភិក្ខុចាស់) អាយតឹ អាវុសោ សំវរេយ្យាសិ ។

(ភិក្ខុខ្ចី) សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

ទុតិយម្បិ សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

តតិយម្បិ សាធុ សត្ថុ ភន្តេ សំវរេយ្យាមិ ។

នបុនេវំ ករិស្សាមិ នបុនេវំ ភាសិស្សាមិ នបុនេវំ ចិន្តយិស្សាមិ។

ព្រះសទ្ធម្មជាស្គរជ័យ ព្រះវិន័យជារាងធំ
ព្រះសូត្រជាខ្សែរ៉ូ ព្រះអភិធម្មជាស្បែកដាស ។

សូមអនុមោទនាបុណ្យ !!!